ខែមិថុនា ឆ្នាំ២០២៤

# កំណែទម្រង់លើគោលការណ៍ណែនាំស្ដីពីនីតិវិធី និងដំណើរការនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា ឆ្នាំ២០១៧៖

ការវិភាគផ្នែកច្បាប់នៅក្នុងបរិបទនៃគោលការណ៍ណែនាំរបស់អាស៊ាន សម្រាប់ក្របខណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាព



CLIENTEARTH.ASIA

ClientEarth

# សេចក្តីផ្តើម

ជាសកល មានការកើនឡើងនៅការយល់ដឹង និងការទទួលស្គាល់ពីតួនាទីយ៉ាងសំខាន់របស់សហគមន៍មូលដ្ឋាន និង ជនជាតិដើមភាគតិច ("IPs") នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងការអភិរក្សជីវចម្រុះ ដែលបញ្ហានេះចាត់ទុកថាជាបញ្ហាបន្ទាន់ ដោយសារតែវិបត្តិភពផែនដីដែលកំពុងកើនឡើង ពោលគឺបញ្ហាដែលទាក់ទងទៅនឹង ការប្រែប្រួលអាកាសធាតុ ការបំពុលបរិស្ថាន និងការបាត់បង់ជីវចម្រុះជាដើម)។ មធ្យោបាយមួយដែលអាចជាសកម្មភាពក្នុងការដោះស្រាយបញ្ហានេះគឺតាមរយៈ ព្រៃសហគមន៍ ("SF") ដែលគ្របដណ្តប់យ៉ាងទូលំទូលាយលើទម្រង់ផ្សេងៗនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ។ គំរូមួយរបស់ព្រៃសហគមន៍គឺសហគមន៍តំបន់ការពារធម្មជាតិ ("CPAs") ដែលនៅក្នុងប្រទេសកម្ពុជាបាននឹងកំពុងលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងអភិរក្ស និងពង្រឹងការអភិវឌ្ឍជីវភាពសហគមន៍មូលដ្ឋាន។

ក្រោយពីការប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនូវក្រមបរិស្ថាន និងធនធានធម្មជាតិឆ្នាំ២០២៣ ("ក្រមបរិស្ថាន") របស់កម្ពុជា, ក្របខណ្ឌច្បាប់ទាក់ទងនឹង តំបន់ការពារធម្មជាតិ ("PAs") និងសហគមន៍តំបន់ការពារធម្មជាតិមានការផ្លាស់ប្តូរ។ កំណែទម្រង់ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលជាដំបូងឡើយគ្រោងថាជាការធ្វើវិសោធនកម្មដោយឡែក ត្រូវបានដាក់បញ្ចូលទៅក្នុង ក្រមបរិស្ថាន។ ជាហេតុ ក្រមបរិស្ថានបច្ចុប្បន្នគឺជាលិខិតបទដ្ឋានគតិយុត្តិចម្បងក្នុងការគ្រប់គ្រង តំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្ម-ជាតិ។ បន្ទាប់ពីក្រមបរិស្ថានត្រូវបានកំណត់ឲ្យចូលជាធរមាននៅចុងខែមិថុនា ឆ្នាំ២០២៤ ក្រសួងបរិស្ថាន ("MoE") កំពុងធ្វើការកែសម្រួលប្រកាសឆ្នាំ២០១៧ស្តីពី គោលការណ៍នាំអំពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ("គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ") ដែលនឹងត្រូវបានប្រើប្រាស់ជាលិខិតបទដ្ឋានគតិយុត្តសម្រាប់ការអនុវត្ត។[1]

គោលបំណងនៃការសិក្សាវិភាគនេះគឺ ដើម្បីវាយតម្លៃគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍ តំបន់ការពារធម្មជាតិ ដោយប្រើប្រាស់គោលការណ៍ណែនាំអាស៊ានសម្រាប់ក្របខណ្ឌច្បាប់ព្រៃសហ-គមន៍ប្រកបដោយប្រសិទ្ធិភាព ("AGP") ដើម្បីដើម្បីផ្តល់នូវការយល់ដឹងដ៏មានប្រយោជន៍សម្រាប់ការកែសម្រួលគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងសម្រាប់ការបង្កើតអនុ-ក្រឹត្យស្តីពីសហគមន៍តំបន់ការពារធម្មជាតិដាច់ដោយឡែកមួយទៀត (ដែលទំនងនឹងប្រើជាលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការអនុវត្ត គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ)។

គោលការណ៍ណែនាំអាស៊ានសម្រាប់ក្របខណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាព គឺជាគោលការណ៍ណែនាំថ្នាក់តំបន់សម្រាប់ក្របខ័ណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាព ដោយគោលការណ៍នេះមានគោលបំណងជួយពង្រឹងច្បាប់ជាតិស្តីពីព្រៃសហគមន៍ គោលនយោបាយ/ច្បាប់ និងបទប្បញ្ញត្តិ និងការអនុវត្តច្បាប់ទាំងនោះនៅក្នុងប្រទេសដែលជាសមាជិកអាស៊ាន (ដែលរួមបញ្ចូលទាំងកម្ពុជាផងដែរ)។ គោលការណ៍ណែនាំអាស៊ានសម្រាប់ក្របខណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាព អាចផ្តល់នូវមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ច្បាប់ និងបទប្បញ្ញត្តិ។ គោលការណ៍ណែនាំអាស៊ានសម្រាប់ក្របខណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាពក៏អាចត្រូវបានប្រើដើម្បីឆ្លុះបញ្ចាំងទៅលើក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ព្រមទាំងដើម្បីវាយតម្លៃថាតើផ្នែកសំខាន់ៗព្រៃសហគមន៍ត្រូវបានដាក់បញ្ចូលហើយឬនៅ ឬក៏តម្រូវឲ្យមានកំណែទម្រង់ច្បាប់។ ដោយសារតែគោលការណ៍

[1] ដើម្បីផ្តល់ជាសាវតា ឋានានុក្រមនៃច្បាប់នៅកម្ពុជាមានដូចខាងក្រោម (ចាប់ផ្តើមពីកម្រិតខ្ពស់បំផុត ដល់កម្រិតទាបបំផុត)៖ ច្បាប់រដ្ឋធម្មនុញ្ញ, ច្បាប់, ព្រះរាជក្រឹត្យ, អនុក្រឹត្យ, ប្រកាសពីក្រសួង, សេចក្តីសម្រេច, សារាចរ, និងដីកា។ ប្រកាស គឺជាបទប្បញ្ញត្តិប្រតិបត្តិ ដែលធ្វើឡើងនៅថ្នាក់ក្រសួង ដើម្បីអនុវត្ត និងបញ្ជាក់អំពីបទប្បញ្ញត្តិជាក់លាក់ណាមួយនៅក្នុងក្របខណ្ឌច្បាប់ថ្នាក់ខ្ពស់ និងផ្តល់ជាការណែនាំ។ វិសាលភាពរបស់ប្រកាសត្រូវបានកំណត់ឲ្យផ្តោតតែលើប្រធានបទបច្ចេកទាក់ទងនឹងក្រសួងដែលចេញប្រកាស។ អនុក្រឹត្យដែលនៅក្នុងឋានានុក្រមនៃច្បាប់ខ្ពស់ជាងប្រកាស គឺជាបទប្បញ្ញត្តិប្រតិបត្តិដែលត្រូវបានប្រើដើម្បីបញ្ជាក់អំពីបទប្បញ្ញត្តិនៅក្នុងច្បាប់ដែលមានស្រាប់ កំណត់មុខងារ និងភារកិច្ចរបស់ស្ថាប័នរដ្ឋាភិបាល និងតែងតាំងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។ អនុក្រឹត្យត្រូវបានព្រាងនៅក្នុងក្រសួងពាក់ព័ន្ធ អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី និងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។

ណែនាំអាស៊ានសម្រាប់ក្របខណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាពមានលក្ខណៈទូទៅសម្រាប់ថ្នាក់តំបន់ គោលការណ៍នេះគួរតែប្រើប្រាស់ និងអនុវត្តទៅតាមបរិបទជាក់លាក់របស់ប្រទេសជាសមាជិក។

នៅក្នុងអត្ថបទវិភាគនេះ គោលការណ៍ណែនាំចំនួន ១០ (និងគោលការណ៍រងពាក់ព័ន្ធ) បានដាក់បង្ហាញសម្រាប់ជាឯកសារយោង/បរិបទ ហើយការវាយតម្លៃគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិទាក់ទងនឹងគោលការណ៍ណែនាំនីមួយៗនឹងត្រូវបានផ្តល់ជូនខាងក្រោម។ អត្ថបទវិភាគនេះមានគោលបំណងផ្តល់ជាព័ត៌មានដល់អង្គការសង្គមស៊ីវិល អ្នកធ្វើគោលនយោបាយ និងភាគីពាក់ព័ន្ធផ្សេងទៀតដែលកំពុងធ្វើការលើ ឬមានចំណាប់អារម្មណ៍លើសហគមន៍តំបន់ការពារធម្មជាតិនៅកម្ពុជា។ បន្ថែមពីនេះទៀត អត្ថបទនេះក៏សម្រាប់ភាគីពាក់ព័ន្ធនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានចំណាប់អារម្មណ៍ដល់ការអនុវត្តគោលការណ៍ណែនាំអាស៊ានសម្រាប់ក្របខណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាពនៅក្នុងបរិបទជាក់លាក់ណាមួយ។



# គោលការណ៍ទី១៖ ការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លី និងព្រៃឈើរបស់សហគមន៍

ក្របខ័ណ្ឌច្បាប់គួរតែធានាថាសហគមន៍ដែលពាក់ព័ន្ធក្នុងព្រៃសហគមន៍មានសិទ្ធិ និងទំនួលខុសរឹងមាំ និងច្បាស់លាស់ត្រូវក្នុងការកាន់កាប់ដីធ្លី ដើម្បីទទួលបានអត្ថប្រយោជន៍ និងរួមចំណែកដល់ការគ្រប់គ្រងព្រៃសហគមន៍ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ព្រមទាំងឆ្លុះបញ្ចាំងពីទំនៀមទម្លាប់ និងការប្រើប្រាស់ព្រៃឈើ និងដីធ្លីរបស់សហគមន៍ រួមបញ្ចូលទាំងជនជាតិដើមភាគតិច និងជនជាតិភាគតិច។

1.1 ក្របខ័ណ្ឌច្បាប់គួរតែទទួលស្គាល់ជាផ្លូវការក្នុងសិទ្ធិកាន់កាប់ព្រៃឈើ និងដីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងជនជាតិភាគតិច រួមមានសិទ្ធិកាន់កាប់ដីធ្លី/ព្រៃឈើតាមប្រពៃណី។ នៅពេលដែលច្បាប់ភូមិបាល និង/ឬច្បាប់ព្រៃឈើទទួលស្គាល់ជាផ្លូវការនូវសិទ្ធិកាន់កាប់ដីធ្លី/ព្រៃឈើតាមប្រពៃណីប្រការនេះគួរតែត្រូវបានឆ្លុះបញ្ចាំង និងទទួលស្គាល់នៅក្នុងច្បាប់ព្រៃសហគមន៍ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការទទួលស្គាល់ជាផ្លូវការនៃសិទ្ធិកាន់កាប់អាចមិនចាំបាច់ ដើម្បីឲ្យសហគមន៍អាចចូលប្រើប្រាស់ច្បាប់ព្រៃសហគមន៍។ លើសពីនេះទៀត ការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិកាន់កាប់របស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ជនជាតិភាគតិចគួរតែតែធ្វើឡើងក្នុងទម្រង់យ៉ាងសាមញ្ញបំផុត។

1.2 ក្នុងករណីដែលគ្មានការទទួលស្គាល់ជាផ្លូវច្បាប់នៃសិទ្ធិប្រពៃណី ក្របខណ្ឌច្បាប់ព្រៃសហគមន៍គួរតែគិតគូរពីសិទ្ធិកាន់កាប់ព្រៃឈើ និងសិទ្ធិកាន់កាប់ដីតាមព្រឹត្តិន័យ ដើម្បីឆ្លុះបញ្ចាំងពីទំនៀមទម្លាប់ និងការប្រើប្រាស់ព្រៃឈើ និងដីធ្លីតាមបែបប្រពៃណីរបស់សហគមន៍។

1.3 ក្របខ័ណ្ឌច្បាប់គួរតែគោរព និងទទួលស្គាល់ចំណេះដឹងប្រពៃណីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងជនជាតិភាគតិច ព្រមទាំងប្រព័ន្ធគ្រប់គ្រងចំណេះដឹង/ចំណេះដឹងរបស់ពួកគេ ថាជាធនធានមួយសម្រាប់សហគមន៍។

1.4 ក្របខ័ណ្ឌច្បាប់ និងស្ថាប័នគួរជួយសម្រួល និងគាំទ្រដល់ការរាប់បញ្ចូលសិទ្ធិដីធ្លី និងធនធានតាមបែបប្រពៃណីរបស់សហគមន៍។

1.5 ក្របខ័ណ្ឌច្បាប់គួរតែផ្តល់នូវអភិក្រមមួយដែលគិតគូរអំពីយេនឌ័រនៅក្នុងព្រៃសហគមន៍ ដើម្បីជាការពារចំពោះប្រព័ន្ធកាន់កាប់ដីធ្លីបែបប្រពៃណីដែលមានវិសមភាព និងដើម្បីការពារសិទ្ធិក្នុងការចូលរួម និងការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រី ជាពិសេសក្រុមដែលមានចំណូលទាប និងសហគមន៍មូលដ្ឋាន និងក្រុមជនជាតិដើមភាគតិច។

1.6 ក្របខណ្ឌច្បាប់គួរតែគូសបញ្ជាក់ឲ្យច្បាស់ពីសិទ្ធិកាន់កាប់ដែលការចូលប្រើប្រាស់ព្រៃសហគមន៍ត្រូវបានផ្អែកលើ ដើម្បីជៀសវាងជម្លោះពាក់ព័ន្ធនឹងសិទ្ធិក្នុងការកាន់កាប់។

1.7 ការទទួលស្គាល់ផ្លូវច្បាប់ពីសិទ្ធិកាន់កាប់ព្រៃឈើ និងដីធ្លីបែបប្រពៃណីគួរតែមានភាពស៊ីសង្វាក់គ្នាជាមួយក្របខណ្ឌច្បាប់ទាំងអស់ ជាពិសេសនៅក្នុងច្បាប់ភូមិបាល និងច្បាប់ស្តីពីព្រៃឈើ ដើម្បីធានាភាពជាក់លាក់ផ្នែកច្បាប់ និងកម្រិតដូចគ្នានៃសុវត្ថិភាពក្នុងការកាន់កាប់។ នៅពេលដែលភាពមិនដូចគ្នា ឬភាពមិនច្បាស់លាស់ត្រូវបានរកឃើញ ដំណើរការធ្វើកំណែទម្រង់ច្បាប់ប្រកបដោយការចូលរួមគួរតែបានប្រព្រឹត្តិឡើងដើម្បីដោះស្រាយបញ្ហានេះ។

1.8 ក្រសួង និងរដ្ឋបាល ដែលទទួលខុសត្រូវចំពោះការទទួលស្គាល់ និងការអនុវត្តសិទ្ធិកាន់កាប់ដីធ្លី និងព្រៃឈើរបស់សហគមន៍គួរតែសម្របសម្រួលជាមួយស្ថាប័នរដ្ឋាភិបាលតាមវិស័យពាក់ព័ន្ធ ដើម្បីធានាថាច្បាប់តាមវិស័យពាក់ព័ន្ធ មានភាពស៊ីសង្វាក់គ្នាជាមួយនឹងក្របខណ្ឌព្រៃសហគមន៍ និងដូចជានេះដែរក្របខណ្ឌព្រៃសហគមន៍ក៏គួរតែស៊ីសង្វាក់គ្នានឹងច្បាប់តាមវិស័យ។ ការសម្របសម្រួលបែបនេះគួរតែធ្វើឡើងទាំងអាជ្ញាធរជាតិ និងថ្នាក់ក្រោមជាតិ។

1.9 រាជរដ្ឋាភិបាលគួរតែធានាថាសិទ្ធិកាន់កាប់ដីធ្លី និងព្រៃឈើ ជាពិសេសសិទ្ធិរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងជនជាតិភាគតិច ដែលបានទទួលស្គាល់ក្នុងច្បាប់ ត្រូវបានគោរពតាម និងអនុវត្ត។ ការអនុវត្តសិទ្ធិបែបនេះគួរតែធ្វើឡើងក្នុងពេលវេលាសមស្របណាមួយ ដូចជាធានាថារចនាសម្ព័ន្ធស្ថាប័នចាំបាច់ត្រូវបានបង្កើតឡើងក្នុងលក្ខណៈទាន់ពេលវេលាក្នុងការអនុវត្តនេះ។

1.10 ការចុះបញ្ជីតំបន់ព្រៃសហគមន៍នៅក្នុងប្រព័ន្ធចុះបញ្ជីដីធ្លីដែលមានស្រាប់ គួរតែជាតម្រូវការ ដើម្បីបង្កើនសុវត្ថិភាពកាន់កាប់ និងធានាឲ្យកាន់តែប្រសើរនូវតម្លាភាព និងការការពារសិទ្ធិ។

## ការវាយតម្លៃ

សិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍តំបន់ការពារធម្មជាតិ អាចត្រូវបានពង្រីកនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល។ ឧទាហរណ៍ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចអនុញ្ញាតឲ្យសហគមន៍តំបន់ការពារធម្មជាតិ អនុវត្តសិទ្ធិ**ផ្តាច់មុខ** (*ឧទាហរណ៍៖* សិទ្ធិហាមឃាត់អ្នកខាងក្រៅក្នុងការចូល ឬប្រើប្រាស់ដីដែលបានបែងចែកជាសហគមន៍តំបន់ការពារធម្មជាតិ សិទ្ធិហាមឃាត់ការប្រើប្រាស់បច្ចេកវិទ្យាមួយចំនួននៅក្នុងព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ)។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឆ្នាំ ២០១៧ អាចពង្រឹងបន្ថែមដោយបញ្ជាក់ពី**ភាពរឹងមាំនៃសិទ្ធិរបស់សហគមន៍**ទាក់ទងនឹងសហគមន៍តំបន់ការពារធម្មជាតិ។ ឧទាហរណ៍ តើសិទ្ធិដែលទាក់ទងនឹង សហគមន៍តំបន់ការពារធម្មជាតិ តទល់នឹងសិទ្ធិកាន់កាប់ផ្សេងៗទៀតយ៉ាងដូចម្តេច? វាអាចជាប្រយោជន៍ដល់សហគមន៍ក្នុងការយល់ដឹងកាន់តែច្បាស់ពីសិទ្ធិរបស់ពួកគេ នៅពេលដែលពួកគេបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងសុវត្ថិភាពដែលសិទ្ធិទាំងនេះបានផ្តល់ឲ្យ។

លើសពីនេះទៅ ទៀតសុវត្ថិភាពផ្នែកច្បាប់របស់សហគមន៍លើដីសហគមន៍តំបន់ការពារធម្មជាតិ អាចពង្រឹងបន្ថែម ប្រសិនបើពួកគេទទួលបាន**លិខិតទទួលស្គាល់ជាផ្លូវការពីសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ** (ដែលអាចរួមបញ្ចូលទៅក្នុងការចុះបញ្ជីសហគមន៍តំបន់ការពារធម្មជាតិ, សូមមើលខាងក្រោម) ដែលអាចបង្កើនអានុភាពរបស់សហគមន៍តំបន់ការពារធម្មជាតិ ប្រសិនបើជម្លោះកើតឡើង។ ជារឿយៗ នៅពេលដែលវិវាទដីធ្លីកើតឡើង សហគមន៍តំបន់ការពារធម្មជាតិប្រឈមមុខនឹងភាគីប្រឆាំងដែលមកពីខាងក្រៅសហគមន៍ ដែលមានមុខតំណែង ឬតួនាទីធំជាង។ ភាគីប្រឆាំងជាធម្មតាតែងមានលិខិតផ្លូវការណាមួយដើម្បីគាំទ្រការទាមទារដីដែលមានវិវាទ ដូចជាប័ណ្ណកម្មសិទ្ធិ កិច្ចព្រមព្រៀងសម្បទាន ឬការទាមទារការប្រើប្រាស់ដែលត្រូវបានទទួលស្គាល់ជាផ្លូវច្បាប់ផ្សេងៗទៀត។

បើទោះបីជា ក្រមបរិស្ថាន[2] តម្រូវឲ្យមានការចុះឈ្មោះតំបន់ការពារធម្មជាតិ[3]ក៏ដោយ ការចុះឈ្មោះរបស់សហគមន៍តំបន់ការពារធម្មជាតិ (អាចជាផ្នែកមួយនៃការចុះឈ្មោះតំបន់ការពារធម្មជាតិ ឬដាច់ដោយឡែក) មិនត្រូវបានបញ្ជាក់ និងត្រូវបានទុកចោល។ បញ្ហានេះគួរតែត្រូវបានបញ្ជាក់បន្ថែមឲ្យច្បាស់លាស់នៅក្នុងការកែសម្រួលគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដោយរួមបញ្ចូលការ**ចុះបញ្ជីសហគមន៍តំបន់ការពារធម្មជាតិ**នៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល។ វាក៏មានអត្ថប្រយោជន៍ផងដែរដែលការចុះបញ្ជីសហគមន៍តំបន់ការពារធម្មជាតិអាចកើតឡើងដោយមិនតម្រូវឲ្យសហគមន៍បំពេញជំហានបន្ថែម ដូចជាអាជ្ញាធរអាចចុះបញ្ជីសហគមន៍តំបន់ការពារធម្មជាតិដោយស្វ័យប្រវត្តនៅពេលបំពេញ/បញ្ចប់ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ឬនៅពេលដែលប្រកាសទទួលស្គាល់សហគមន៍ត្រូវបានចេញ។ ការចុះបញ្ជីតំបន់ការពារធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ នៅក្នុងប្រព័ន្ធចុះបញ្ជីកណ្តាលអាចកាត់បន្ថយ ឬលុបចោលហានិភ័យនៃការទាមទារដីធ្លីជាន់គ្នា។

ប្រសិនបើសមស្រប **ការអនុញ្ញាតឲ្យចូលប្រើប្រាស់ធនធានធម្មជាតិដែលមានលក្ខណៈបែបប្រពៃណីរបស់សហគមន៍មូលដ្ឋាន[4] ជាទម្រង់គ្រួសារនៅក្នុងតំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងតំបន់អភិរក្ស** គួរតែត្រូវបានលើកឡើងនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្ម-ជាតិដែលត្រូវបានកែសម្រួល ដោយក្រមបរិស្ថានបានចែងថានឹងអនុវត្តតាមគោលការណ៍ណែនាំដែលមានចែងក្នុងប្រកាសនាពេលអនាគត ដែលចេញដោយក្រសួងបរិស្ថា។[5] គោលការណ៍ណែនាំបែបនេះអាចត្រូវបានរួមបញ្ចូលនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ឬនៅក្នុងប្រកាសដាច់ដោយឡែកមួយ។

[2] សម្រាប់ការវិភាគនេះ ការបកប្រែក្រៅផ្លូវការរបស់ក្រមបរិស្ថាន និងធនធានធម្មជាតិត្រូវបានប្រើប្រាស់។

[3] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៥១, ៣៦៧។ ការចុះបញ្ជីនេះអាចសន្មតថានៅក្នុងបញ្ជីភូមិបាល និងអាចជានៅក្នុងបញ្ជីអចលនទ្រព្យ និងមូលដ្ឋានទិន្នន័យរដ្ឋពាក់ព័ន្ធផ្សេងទៀត។.

[4] នៅក្នុងបរិបទនៃក្រមបរិស្ថាន និងធនធានធម្មជាតិ "សហគមន៍មូលដ្ឋាន" ត្រូវបានកំណត់ថាជាសហគមន៍ ដែលរស់នៅក្នុង ឬក្បែរតំបន់ការពារធម្មជាតិ។ ពួកគេអាចត្រូវបានបង្កើតឡើង និងទទួលស្គាល់ថាជាសហគមន៍តំបន់ការពារសហគមន៍ សហគមន៍ព្រៃឈើ ឬសហគមន៍នេសាទ (ទោះបីជាពួកគេមិនចាំបាច់ក៏ដោយ) ឬត្រូវបានទទួលស្គាល់ជាសហគមន៍ដោយច្បាប់ ដូចជាសហគមន៍ជនជាតិដើមភាគតិច។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ "សហគមន៍មូលដ្ឋាន" នៅក្នុងអត្ថបទវិភាគនេះគួរតែត្រូវបានយល់ថាជាការសំដៅទៅលើសហគមន៍មូលដ្ឋានយ៉ាងទូលំទូលាយ/ជាទូទៅ។

[5] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៦៩

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចទទួលស្គាល់**ចំណេះដឹងប្រពៃណី** របស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងជនជាតិភាគតិច ព្រមទាំងទទួលស្គាល់ប្រព័ន្ធគ្រប់គ្រងចំណេះដឹង/ចំណេះដឹងរបស់ពួកគេជាធនធានមួយរបស់សហគមន៍។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចជួយសម្រួល និងគាំទ្រដល់**ការរាប់បញ្ចូលសិទ្ធិកាន់កាប់ដីធ្លី និងធនធានតាមលក្ខណៈប្រពៃណី**។ ក្រមបរិស្ថានណែនាំក្រសួងបរិស្ថាន ឲ្យបង្កើតផែនទីផ្លូវការសម្រាប់តំបន់ការពារធម្មជាតិនីមួយៗ ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន។[6] ផែនទីបែបនេះអាចរាប់បញ្ចូលទាំងសិទ្ធិកាន់កាប់ដីធ្លី និងធនធានតាមលក្ខណៈប្រពៃណី ទៅក្នុងផែនទីតំបន់ការពារធម្មជាតិ ដោយមានការចូលរួមពេញលេញពីសហគមន៍មូលដ្ឋាន។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចផ្តល់នូវការណែនាំបន្ថែមលើការដាក់បញ្ចូលសិទ្ធិសិទ្ធិកាន់កាប់ដីធ្លី និងធនធានតាមលក្ខណៈប្រពៃណីនៅក្នុងផែនទីផ្លូវការរបស់តំបន់ការពារធម្មជាតិ ក៏ដូចជាណែនាំអំពីរបៀបដែលការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានអាចត្រូវបានធ្វើឡើង។

លើសពីនេះទៅទៀត **ការបែងចែកតំបន់នៃ តំបន់ការពារធម្មជាតិប្រកបដោយការចូលរួម** (ដែលសន្មតថានឹងត្រូវបានរួមបញ្ចូលនៅក្នុងផែនទីតំបន់ការពារធម្មជាតិផ្លូវការ) អាចមានសារៈសំខាន់។ ដោយសារការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបានអនុញ្ញាតឲ្យធ្វើឡើងតែនៅក្នុងតំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងតំបន់សហគមន៍នៃតំបន់ការពារធម្មជាតិ ការចូលរួមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចនៅក្នុងការកំណត់ការបែងចែកតំបន់របស់តំបន់ការពារធម្មជាតិទាំងមូលគួរតែទទួលបានការពិចារណា។ វាអាចត្រូវបានលើកឡើងនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ដោយមានការណែនាំអំពីរបៀប ដែលសហគមន៍មូលដ្ឋាន ជនជាតិភាគតិច និងជនជាតិដើមភាគតិចអាចចូលរួមនៅក្នុងការបែងចែកតំបន់ការពារធម្មជាតិ។ ក្នុងករណីដែលការបែងចែកតំបន់ការពារធម្មជាតិកើតឡើងនៅក្នុងទីតាំងដែលមានការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់ពីការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការបែងចែកតំបន់ការពារធម្មជាតិ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិអាចត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឲ្យចូលរួមយ៉ាងសកម្ម និងសហការជាមួយអាជ្ញាធររដ្ឋាភិបាល**នៅក្នុងផ្នែកទាំងអស់នៃការធ្វើផែនទីធនធាន ការធ្វើផែនការប្រើប្រាស់ដី ការកំណត់តំបន់ ការធ្វើផែនការគ្រប់គ្រង និងការល្បាតរួមគ្នានៃតំបន់ការពារធម្មជាតិ**។ ទាំងនេះអាចត្រូវបានលើកឡើងនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចសង្កត់ធ្ងន់លើ**អភិក្រមយល់ដឹងអំពីយេនឌ័រ**ចំពោះការបង្កើត និងការអនុវត្តសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីឲ្យសិទ្ធិចូលរួម និងការសម្រេចចិត្តរបស់ស្ត្រីត្រូវបានការពារ និងពង្រឹងបន្ថែម។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិកាន់កាប់របស់សហគមន៍តំបន់ការពារធម្មជាតិ រួមទាំងសិទ្ធិដែលមាននៅក្នុងក្រមបរិស្ថាន ព្រមទាំងបញ្ជាក់**ពីរបៀបដែលសិទ្ធិកាន់កាប់របស់សហគមន៍សហគមន៍តំបន់ការពារធម្មជាតិ មានទំនាក់ទំនងជាមួយសិទ្ធិ/សកម្មភាពដទៃទៀត**។ ឧទាហរណ៍ តើសកម្មភាព/គម្រោងដែលត្រូវបានអនុញ្ញាតនៅក្នុងតំបន់ការពារធម្មជាតិ (*ឧ.* ការអភិវឌ្ឍន៍គម្រោងទេសចរណ៍ធម្មជាតិ កីឡាបរបាញ់)[7] និង

[6] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៦៧

[7] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧៨

គម្រោងសាធារណៈ ឬឯកជននៅក្នុងតំបន់ការពារធម្មជាតិ (*ឧ.* ការសាងសង់ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ)[8] ដំណើរការដោយរបៀបណាទាក់ទងទៅនឹងសហគមន៍តំបន់ការពារធម្មជាតិ?

ការទទួលស្គាល់ផ្លូវច្បាប់នៃសិទ្ធិកាន់កាប់ព្រៃឈើ និងសិទ្ធិកាន់កាប់ដីធ្លីមានលក្ខណៈប្រពៃណីគួរតែមាន**ភាពស៊ីសង្វាក់គ្នា**ជាមួយក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ សម្រាប់ការកែសម្រួលគោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ការចុះសម្រុងគ្នាជាមួយក្រមបរិស្ថានប្រហែលជាត្រូវការជាចាំបាច់។ ប្រសិនបើមានច្បាប់ផ្សេងទៀត (*ឧ.* ច្បាប់ស្ដីពីព្រៃឈើដែលបានធ្វើកំណែទម្រង់ (កំពុងបន្ត) ច្បាប់ភូមិបាលដែលបានធ្វើកំណែទម្រង់) មានការពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិក្នុងសមត្ថភាពណាមួយ នោះការចុះសម្រុងគ្នាជាមួយនឹងច្បាប់បែបនេះក៏អាចជាការចាំបាច់ផងដែរ។

ជាមួយនឹងការអនុម័តនាពេលថ្មីៗនេះនៃក្រមបរិស្ថាន និងការផ្ទេរតួនាទី និងការទទួលខុសត្រូវយ៉ាងច្រើនដល់អាជ្ញាធរថ្នាក់ក្រោមជាតិដែលកំណត់ដោយក្រមបរិស្ថាន គោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលប្រហែលជាត្រូវ**បញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធររដ្ឋាភិបាល ដែលពាក់ព័ន្ធ**។

ការកែសម្រួលគោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិអាចត្រូវបានអមដោយ**ការបង្កើតរចនាសម្ព័ន្ធស្ថាប័នចាំបាច់ណាមួយក្នុងពេលវេលាសមស្រប** ដើម្បីឲ្យការអនុវត្តអាចប្រព្រឹត្តទៅឡើងបានយ៉ាងត្រឹមត្រូវ និងត្រូវបានអនុវត្ត។

**ការបោះបង្គោលព្រំប្រទល់ច្បាស់លាស់**ត្រូវបានកំណត់ថាជាកត្តាសំខាន់ដែលអនុញ្ញាតឲ្យមានការអនុវត្ត។ បច្ចុប្បន្ននេះ ការបោះបង្គោលព្រំប្រទល់មិនច្បាស់លាស់ ឬមិនមានព្រំប្រទល់ ឬកង្វះខាតក្នុងការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធអំពីទីតាំងរបស់ព្រំប្រទល់ នាំឲ្យមានការបំពានជាញឹកញាប់ និងការទន្ទ្រានកាន់កាប់ជាអចិន្ត្រៃយ៍។ ការចុះឈ្មោះសហគមន៍តំបន់ការពារធម្មជាតិប្រសិនបើអាចលើកឡើងនៅក្នុងគោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអាចបំពេញតម្រូវការសម្រាប់ការមានប្រព័ន្ធមូលដ្ឋានទិន្នន័យ ដែលមានព័ត៌មានគ្រប់គ្រាប់ពាក់ព័ន្ធនឹងព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ។ ព័ត៌មានទាំងនេះអាចអមជាមួយការបោះបង្គោលព្រំប្រទល់របស់សហគមន៍តំបន់ការពារធម្មជាតិដោយផ្ទាល់។

[8] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧៩



## គោលការណ៍ទី ២៖ សម្រួលដល់ដំណើរការនៃការបែងចែកតំបន់ព្រៃសហគមន៍



ក្របខ័ណ្ឌច្បាប់គួរតែផ្តល់នូវដំណើរការដ៏សាមញ្ញ និងមានតម្លៃធូរថ្លៃ ដើម្បីបែងចែកតំបន់ព្រៃសហគមន៍ ដើម្បីធានាបាននូវការចូលប្រើប្រាស់ព្រៃសហគមន៍ដ៏ល្អសម្រាប់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងជនជាតិភាគតិច។ ក្របខ័ណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យសហគមន៍អនុវត្តនីតិវិធីដោយខ្លួនឯង ឬស្វែងរកការគាំទ្រពីខាងក្រៅទៅតាមការចង់បាន។

2.1 ក្របខ័ណ្ឌច្បាប់គួរតែបញ្ជាក់យ៉ាងច្បាស់ថាអ្នកណាអាចបែងចែកតំបន់ព្រៃសហគមន៍នៅក្រោមលក្ខខណ្ឌណាមួយ ហើយសហគមន៍គួរតែមានទម្រង់បែបណាដើម្បីទទួលបានការបែងចែកតំបន់ព្រៃសហគមន៍។ ក្របខ័ណ្ឌច្បាប់ក៏គួរតែបញ្ជាក់ឲ្យច្បាស់ផងដែរ ថាតើមានការកំណត់ភូមិសាស្ត្រអ្វីខ្លះសម្រាប់ការបែងចែកតំបន់ព្រៃសហគមន៍ (ដូចជាដែនព្រៃឈើជាក់លាក់ដែលព្រៃសហគមន៍អាចបង្កើតបាន និងការកំណត់ទំហំ) ក៏ដូចជារយៈពេលកំណត់ណាមួយ។

2.2 ក្របខ័ណ្ឌច្បាប់គួរតែគូសបញ្ជាក់យ៉ាងច្បាស់អំពីជំហាននៃដំណើរការបែងចែក រួមទាំងឯកសារបច្ចេកទេសដែលតម្រូវឲ្យដាក់ជូនដោយសហគមន៍។ ក្របខណ្ឌច្បាប់គួរតែបញ្ជាក់ពីពេលវេលាផុតកំណត់/រយៈពេលនៅក្នុងជំហាននីមួយៗក្នុងការទទួលបានសេចក្តីសម្រេចចិត្ត។

2.3 ក្របខ័ណ្ឌច្បាប់គួរតែកំណត់យ៉ាងច្បាស់នូវស្ថាប័ន ដែលទទួលបន្ទុកដំណើរការដាក់ពាក្យស្នើសុំព្រៃសហគមន៍  និងនៅពេលណាដែលតម្រូវឲ្យមានការសម្របសម្រួលដោយស្ថាប័ន។ ស្ថាប័ន ដែលមានទំនួលខុសត្រូវគួរតែត្រូវបានគាំទ្រ ដោយទទួលបានកម្មវិធីពង្រឹងសមត្ថភាពគ្រប់គ្រាន់ ដើម្បីធានាថាដើម្បីធានាថាពួកគេមានការបណ្តុះបណ្តាល និងជំនាញគ្រប់គ្រាន់ក្នុងការធ្វើការទំនាក់ទំនងជាមួយសហគមន៍ប្រកបដោយប្រសិទ្ធិភាព និងអាចអនុវត្តភារកិច្ចរបស់ពួកគេ។

2.4 ដែលសំណើបង្កើតព្រៃសហគមន៍ត្រូវបានច្រានចោល ក្របខ័ណ្ឌច្បាប់គួរតែតម្រូវឲ្យរដ្ឋបាលពាក់ព័ន្ធផ្តល់ជាមូលហេតុពន្យល់ពីការបដិសេធ។ សហគមន៍ក៏គួរតែត្រូវបានផ្តល់ឱកាសមួយ ដើម្បីធ្វើការកែសម្រួលសំណើរបស់ពួកគេ។

2.5 ដើម្បីសម្រួល និងបញ្ជាក់អំពីដំណើរការបែងចែក រដ្ឋាភិបាលក៏គួរតែអនុម័តគោលការណ៍ណែនាំ ឬគំនូរប្រតិបត្តិការផ្លូវការ ឬមិនផ្លូវការ ដើម្បីជួយពន្យល់និងណែនាំអ្នកដាក់ពាក្យសុំអំពីដំណើរការនៃការបែងចែកនេះ។ គោលការណ៍ណែនាំទាំងនេះគួរតែមានលក្ខណៈរសើបទាក់ទងនឹងវប្បធម៌ និងយេនឌ័រ ហើយត្រូវបកប្រែជាភាសាក្នុងតំបន់ ប្រសិនបើអាចធ្វើបាន។

2.6 វិមជ្ឈការនៃដំណើរការបែងចែក ដោយមានរដ្ឋបាលមូលដ្ឋាន និងអ្នកតំណាងរដ្ឋាភិបាលមដើរតួនាទីកណ្តាលក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត គួរតែត្រូវពិចារណាថាជាយន្តការមួយដើម្បីធានាបាននូវនីតិវិធីសាមញ្ញ ងាយស្រួលប្រើប្រាស់ និងមានប្រសិទ្ធភាពជាងមុន។

2.7 ក្របខ័ណ្ឌច្បាប់គួរតែគូសបញ្ជាក់យ៉ាងច្បាស់អំពីហេតុផល និងលក្ខខណ្ឌ ដែលតំបន់ព្រៃសហគមន៍ ដែលបានបង្កើតហើយ អាចត្រូវបានលុបចោល ហើតក៏គួរតែតម្រូវឲ្យផ្តល់នូវហេតុផលច្បាស់លាស់ពីការលុបចោលនេះ។ បខ័ណ្ឌច្បាប់គួរតែរួមបញ្ចូលនូវជំនួយ ដែលមានសម្រាប់សហគមន៍សម្រាប់តវ៉ាសេចក្តីសម្រេចចិត្ត ដូចជាយន្តការបណ្តឹងសារទុក្ខជាដើម។ សហគមន៍គួរតែត្រូវបានផ្តល់សំណង ប្រសិនបើការលុបចោលនេះមិនផ្អែកលើកំហុសរបស់សហគមន៍។

2.8 ក្របខ័ណ្ឌច្បាប់គួរតែធានាឲ្យមានតម្លាភាពក្នុងអំឡុងពេលធ្វើដំណើរការបែងចែក ដូចជាតម្រូវឲ្យមានការចែករំលែកព័ត៌មានអំពីដំណើរការ និងដោយការផ្តល់យន្តការសម្រាប់អ្នកចាប់អារម្មណ៍ក្នុងការផ្តល់យោបល់ ឬលើកការជំទាស់។

# ការវាយតម្លៃ

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលដែលបានកែប្រែ គួរតែឆ្លុះបញ្ចាំងពីការកើនឡើង នៃរយៈពេលរបស់សហគមន៍តំបន់ការពារធម្មជាតិទៅ២៥ឆ្នាំ ដូចដែលបានចែងក្នុងក្រមបរិស្ថាន។[9] ទោះជាយ៉ាងណាក៏ដោយ ថាតើ**ការបន្តអាច**ធ្វើទៅបានឬមិនបាន *មិនមាន*បញ្ជាក់នៅក្នុងក្រមបរិស្ថាននោះទេ។ ដូច្នេះ វាគួរតែត្រូវបានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល។[10] អ្វីដែលគួរតែពិចារណាបន្ថែមគឺមិនត្រឹមតែផ្តល់ជាជម្រើសក្នុងការបន្តសហគមន៍តំបន់ការពារធម្មជាតិនោះទេ តែក៏ធានាថាសំណើបន្តនឹងទទួលបានការយល់ព្រម (ដរាបណាសហគមន៍នៅតែមានចំណាប់អារម្មណ៍ និងមិនមានបញ្ហាសំខាន់ជាមួយការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ ដែលមិនអាចដោះស្រាយបាន)។ នេះអាចពង្រឹងសិទ្ធិកាន់កាប់របស់សហគមន៍តំបន់ការពារធម្មជាតិបន្ថែមទៀត ព្រមទាំងផ្តល់នូវសុវត្ថិភាពជាងមុន និងការលើកទឹកចិត្តក្នុងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិរយៈពេលវែងប្រកបដោយប្រសិទ្ធភាព។ ជាទូទៅ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចដាក់នៅបទប្បញ្ញត្តិបន្ថែមចំពោះការបន្តសហគមន៍តំបន់ការពារធម្មជាតិ ដូចជាលើរយៈពេលនៃអាណត្តិដែលអាចបន្ត ថាតើវាមាន

[9] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧១

[10] បច្ចុប្បន្នការបន្តឡើងវិញត្រូវបានអនុញ្ញាតនៅក្នុងមាត្រា ៣៣ នៃគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឆ្នាំ២០១៧. ថាតើនឹងមានការផ្លាស់ប្តូរការបន្តឡើងវិញ (ដំណើរការ អាជ្ញាធរពាក់ព័ន្ធ។ល។) គួរតែទទួលបានការពិចារណ ហើយបន្ទាប់មកត្រូវបានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួល។

ការកំណត់ដែរឬទេលើចំនួនដងដែលការបន្តអាចធ្វើបាន លក្ខខណ្ឌដែលសេចក្ដីសម្រេចចិត្តបន្តផ្អែកលើ ពេលវេលាដែលអាជ្ញាធរត្រូវធ្វើការសម្រេចចិត្ត លទ្ធផលប្រសិនបើមានការខ្វះខាតក្នុងការឆ្លើយតបទាក់ទងនឹងសំណើបន្ត (បើអាចវាគួរតែជាការយល់ព្រមបន្តដោយស្វ័យប្រវត្ត ដើម្បីជម្រុញឲ្យអាជ្ញាធរដំណើការ/ពិនិត្យសំណើបន្តទាន់ពេលវេលា និងធានាអាទិភាពដល់ប្រយោជន៍សហគមន៍តំបន់ការពារធម្មជាតិ)។ល។

នៅក្រោមក្រមបរិស្ថាន **អាជ្ញាធរថ្នាក់ក្រោមជាតិ**មានតួនាទីយ៉ាងច្រើននៅក្នុងការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (អាជ្ញាធរថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការបង្កើតកិច្ចព្រមព្រៀងសម្រាប់សហគមន៍តំបន់ការពារធម្មជាតិនៅក្នុងតំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព នៃតំបន់ការពារធម្មជាតិ; អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវចាប់ផ្ដើម សម្របសម្រួល គាំទ្រ ផ្ដល់គោលការណ៍ និងទទួលស្គាល់ការបង្កើតសហ-គមន៍តំបន់ការពារធម្មជាតិ បន្ទាប់ពីមានការយល់ព្រមពីក្រសួងបរិស្ថាន; អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវធ្វើការសិក្សាពីលទ្ធភាពនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ កំណត់ទីតាំង និងទំហំសមស្រប រួមទាំងធ្វើការការពិគ្រោះយោបល់ និងការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត)។[11] ការបែកចែកទំនួលខុសត្រូវនេះគួរតែដាក់បញ្ចូលនៅក្នុងគោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ហើយព័ត៌មានលម្អិតបន្ថែមទៀតអាចមានជាសារៈប្រយោជន៍។[12]

ក្រសួងបរិស្ថានមានតួនាទីផ្ដល់**ការពង្រឹងសមត្ថភាព និងគាំទ្រផ្នែកបច្ចេកទេស** ដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន[13] ហើយតួនាទីរបស់ក្រសួងបរិស្ថាននេះអាចដាក់បញ្ចូល និងពង្រីកបន្ថែមនៅក្នុងគោលការណ៍សហគមន៍តំបន់ការពារធម្មជាតិដែលបានធ្វើកំណែទម្រង់។

ក្រមបរិស្ថានមិនបានបញ្ជាក់ឲ្យច្បាស់ថា**អនុក្រឹត្យស្ដីពីយន្តការបង្កើតនាពេលអនាគត សហគមន៍តំបន់ការពារធម្មជាតិនាពេលអនាគត**នឹងផ្ដោតលើខ្លឹមសារអ្វីខ្លះ៖[14] ហើយ**ប្រកាស/គោលការណ៍ស្ដីពីនីតិវិធី និងដំណើរសហគមន៍តំបន់ការពារធម្មជាតិ**នឹងផ្ដោតលើខ្លឹមសារអ្វី។[15] ប្រកាសដែលបានលើកឡើងខាងលើគឺត្រូវបានចាត់ទុកថាសំដៅទៅលើគោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ បញ្ហានេះគួរតែទុកជាការពិចារណាក្នុងពេលធ្វើការកែសម្រួលគោលការណ៍ណែនាំស្ដីពីការបង្កើតសហ-គមន៍តំបន់ការពារធម្មជាតិ (ដើម្បីធានាភាពស្រុះសម្រុង និងការពារការមានចន្លោះប្រហោង។ល។)។

សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រពួកគេបានចាត់ទុកដំណើការបង្កើតសហគមន៍តំបន់ការពារធម្មជាតិថាមានរយៈពេលយូរអន្លាយ ស្មុគស្មាញ និងត្រូវការចំណាយច្រើន។ **ជំហាននៃការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ** គួរតែមានភាពសាមញ្ញជាងមុននៅក្នុងគោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល។ ឧទាហរណ៍ ផែនទីដែលជាតម្រូវការអាចកាត់បន្ថយតម្រូវការបច្ចេកទេសជាងមុន និងផ្អែកលើផែនទីគម្រូដែលបង្កើតឡើងដោយសហ-គមន៍ ហើយផែនការគ្រប់គ្រងដ៏សាមញ្ញដែលបង្កើតឡើងដោយសហគមន៍គួរតែគ្រប់គ្រាន់។

[11] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៥២, ៣៧១

[12] ជាការផ្ដល់ព័ត៌មានបន្ថែមពីតួនាទី និងទំនួលខុសត្រូវរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិគួរតែកែសម្រួលដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្ដូរទាក់ទងនឹងស្ថាប័នដែលទទួលខុសត្រូវ ដែលបានចែងនៅក្នុង គោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឆ្នាំ២០១៧។ ឧទាហរន៍ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន (ប្រការ ៤), នាយកដ្ឋានជីវភាពសហគមន៍ (ប្រការ ៥), មន្ទីរបរិស្ថានខេត្ត (ប្រការ ៦), នាយកតំបន់ការពារធម្មជាតិ (ប្រការ ៧), សមាសភាពក្រុមការងារ (ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (CPA), ជំពូក ១.១), សមាសភាពក្រុមការងារបច្ចេកទេស (ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (CPA), ជំពូក ២.១)។ល។

[13] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៥១

[14] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧១(៨)

[15] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧១(៩)

យោងតាម**រចនាសម្ព័ន្ធបច្ចុប្បន្ន** ដំណើរបង្កើតសហគមន៍តំបន់ការពារធម្មជាតិតម្រូវឲ្យសមាជិកសហគមន៍ដែលចូលរួមធ្វើការបំពេញលិខិតសុំចូលជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិ; លិខិតស្នើសុំរៀបចំសហគមន៍តំបន់ការពារធម្មជាតិ; ការបោះឆ្នោតជ្រើសរើសគណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិ (រួមមានដីកាចេញពីមេឃុំ/ចៅសទទួលស្គាល់គណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិ); ការកំណត់ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ (រួមទាំងផែនទីរបស់សហគមន៍តំបន់ការពារធម្មជាតិ ដែលបានធ្វើតាមមាត្រដ្ឋានទទួលស្គាល់ជាផ្លូវការ); ការបង្កើតលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ; ប្រកាសទទួលស្គាល់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលចេញដោយក្រសួងបរិស្ថាន; ការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងការបង្កើតកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។[16] ទោះជាយ៉ាងណាក៏ដោយ ដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិទាំង ៧ជំហានមិនតែងតែត្រូវបានអនុវត្តនោះទេ ដោយជាក់ស្តែងដំណើរការបង្កើតអាចមានភាពបត់បែនជាងនេះ និងជាក់ស្តែងតាមករណីរបស់សហគមន៍តំបន់ការពារធម្មជាតិនីមួយៗ។

សហគមន៍បានសម្តែងការមិនពេញចិត្តចំពោះដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិនេះ ដោយសារតែដំណើរការនេះទាមទារ**ឲ្យបញ្ចប់ច្រើនជំហាន និងមានអាជ្ញាធរជាច្រើនចូលរួម**។ វាពិតជាមានការលំបាកណាស់សម្រាប់សហគមន៍ក្នុងការធ្វើតាម និងបញ្ចប់ដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដោយខ្លួនឯង។ ជំហាននីមួយៗតម្រូវឲ្យមានការដាក់ពាក្យពីសហគមន៍ និងការទទួលស្គាល់ពីអាជ្ញាធរ ហើយស្ទើរតែគ្រប់ជំហានតម្រូវឲ្យមានការចូលរួមពីអាជ្ញាធររដ្ឋាភិបាលសម្រាប់ការប្រឹក្សា ឬជំនួយផ្នែកបច្ចេកទេស។ **ការពន្យារពេលកើតឡើងជាញឹកញាប់** ដោយសារតែមូលហេតុដូចជាកង្វះខាតសមត្ថភាពរបស់សហគមន៍ កង្វះខាតបច្ចេកទេស ហិរញ្ញវត្ថុ និងធនធានមនុស្សពីអាជ្ញាធរ និងដំណោះស្រាយជម្លោះដីធ្លី។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលគួរតែផ្តល់**ពេលវេលាកំណត់**សម្រាប់អាជ្ញាធរក្នុងការធ្វើការសម្រេចពាក្យសុំរបស់សហគមន៍នៅក្នុងដំណើរការនីមួយៗនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ឬក៏យ៉ាងហោចណាស់ផ្តល់ការប៉ាន់ស្មាននូវរយៈពេលទាំងមូលដែលការសម្រេចចិត្តលើការបង្កើតសហគមន៍តំបន់ការពារធម្មជាតិត្រូវបានសម្រេច។គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលគួរតែបញ្ជាក់ថាតើការមិនទទួលបានការឆ្លើយតបទាក់ទងនឹងលទ្ធផលរដ្ឋបាលគឺជាការយល់ព្រម ឬការបដិសេធនៃសំណើបង្កើតសហគមន៍តំបន់ការពារធម្មជាតិ (សហគមន៍គួរតែទទួលបានការគាំទ្រ ប្រសិនបើសំណើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិត្រូវបានបដិសេធ ក៏ដូចជាទទួលបានការណែនាំពីការគាំទ្រនានាដែលមាន)។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលគួរតែបញ្ជាក់បន្ថែមពី**លក្ខខណ្ឌសម្រាប់ការយល់ព្រម ឬបដិសេធ**នៃសំណើបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ក៏ដូចជា**បញ្ជាក់ពីជម្រើសដែលសហគមន៍មានប្រសិនបើសំណើបង្កើតសហគមន៍តំបន់ការពារធម្មជាតិរបស់គេត្រូវបានបដិសេធ** ដូចជាយន្តការបណ្តឹងឧទ្ធរណ៍ ឬលទ្ធភាពក្នុងការដាក់ស្នើឡើងវិញនូវសំណើបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួល។ លក្ខខណ្ឌសម្រាប់ការយល់ព្រម ឬបដិសេធការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ក៏អាចជាកត្តាសម្រាប់អ្នកធ្វើការសម្រេចចិត្តក្នុងការពិចារណាក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ លក្ខខណ្ឌនេះផងដែរអាចធ្វើការពិនិត្យឡើងវិញ នៅក្នុងករណីដែលយន្តការបណ្តឹងឧទ្ធរណ៍ (ប្រសិនបើមាន) ត្រូវបានប្រើប្រាស់។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលក៏គួរតែតម្រូវឲ្យមានការផ្តល់**យុត្តិកម្ម**ដោយអាជ្ញាធររដ្ឋាភិបាលសម្រាប់ការបដិសេធសំណើបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ យុត្តិកម្មជាលាយលក្ខណ៍អក្សរស្តីពីការបដិសេធអាចមានសារៈសំខាន់សម្រាប់ដំណើរការបណ្តឹងឧទ្ធរណ៍ និងដំណើរការពិនិត្យរដ្ឋបាល ខ

[16] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ១២, ៣២; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំ, ជំពូកទី ១-៧ (បានរៀបរាប់ពីជំហានទាំង៧ក្នុងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ)

ណៈពេលដែលកំពុងផ្តល់ដំណឹងជូនសហគមន៍អំពីចន្លោះប្រហោងក្នុងសំណើបង្កើតសហគមន៍តំបន់ការពារធម្មជាតិរបស់ពួកគេ។ ជាមួយនឹងព័ត៌មាននេះ សហគមន៍អាចសម្រួលខ្លួន និងដាក់ការស្នើសុំថ្មីដែលបានកែសម្រួលហើយ។

ដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិក៏មានតម្លៃថ្លៃសម្រាប់សហគមន៍។ ទោះបីជាពាក្យសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិគឺមិនគិតកម្រៃ **ការចំណាយប្រតិបត្តិការ**ផ្សេងៗត្រូវបានចំណាយនៅក្នុងដំណើរការដាក់ពាក្យ។ ឧទាហរណ៍ដូចជាការចំណាយលើការធ្វើដំណើរ ដើម្បីរៀបចំការពិគ្រោះយោបល់រវាងអាជ្ញាធរ និងសហគមន៍ និងការចំណាយមូលដ្ឋានសម្រាប់ការបោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ។ បន្ទុកហិរញ្ញវត្ថុទាំងនេះភាគច្រើនចំណាយដោយអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រសហគមន៍ក្នុងការដាក់សំណើ ដោយសារតែការចំណាយទាំងនោះអាចជាបន្ទុកធ្ងន់ធ្ងរសម្រាប់សហគមន៍ក្នុងការរាប់រងតែឯង។

បញ្ហាប្រឈមដែលបានលើកឡើងខាងលើគួរតែត្រូវបានពិចារណា ជាពិសេសនៅពេលដែលដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិកំពុងតែត្រូវបានពិនិត្យ និងសម្រាយនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល។ ការកែសម្រួលទាំងនោះអាចមានកំណែប្រែដំណើរការនេះ ដើម្បី**សម្រាយដល់ភស្តុភាររដ្ឋបាល និងកែលម្អបញ្ហាប្រឈម**ដែលសហគមន៍កំពុងជួបប្រទះ (ពេលវេលា ការចំណាយ ។ល។)។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចរួមបញ្ចូល**គោលការណ៍ណែនាំ ឬក្រាហ្វិកប្រតិបត្តិការ** ដើម្បីជួយពន្យល់ដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ គោលការណ៍ណែនាំទាំងនេះផងដែរក៏គួរតែមាន**លក្ខណៈរសើបអំពីវប្បធម៌ និងយេនឌ័រ** ព្រមទាំងធ្វើការបកប្រែនៅក្នុង**ភាសាភាគតិចនៅក្នុងស្រុក**។ ជាឧទាហរណ៍ បញ្ហាភាសាជាបញ្ហាប្រឈមសម្រាប់សហគមន៍ជនជាតិដើមភាគតិច។

**ឧបសម្ព័ន្ធ**នៃគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឆ្នាំ ២០១៧រួមមាន៖ គំរូលិខិតសុំចូលសមាជិកសហគមន៍តំបន់ការពារធម្មជាតិ (ឧបសម្ព័ន្ធទី ១); គំរូលិខិតស្នើសុំរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ (ឧបសម្ព័ន្ធទី ២); គំរូលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ (ឧបសម្ព័ន្ធទី ៣); គំរូសម្រាប់ការសរសេរផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ (ឧបសម្ព័ន្ធទី ៤); គំរូកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ (ឧបសម្ព័ន្ធទី ៥); គំរូក្របខណ្ឌសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ (ឧបសម្ព័ន្ធទី ៦); និងគំរូរបាយការណ៍សម្រាប់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ (ឧបសម្ព័ន្ធទី ៧)។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលគួរតែបញ្ជាក់ឲ្យច្បាស់ថាសហគមន៍អាចប្រើប្រាស់ឧបសម្ព័ន្ធទាំងនោះដោយរបៀបណា (ឧទាហរណ៍ តើពួកគេត្រូវធ្វើតាមឯកសារគំរូទាំងនោះដល់កម្រិតណា? តើឯកសារគំរូទាំងនេះគ្រាន់តែជាការផ្តល់យោបល់ ឬត្រូវបានរំពឹងថាសហគមន៍នឹងចម្លងគំរូដែលបានផ្តល់ឲ្យ?)។ ដើម្បីផ្តល់នូវការចូលរួម និងភាពបត់បែនបន្ថែមសម្រាប់សហគមន៍ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់ឲ្យច្បាស់ថា**ទម្រង់គំរូ និងឯកសារទាំងនោះគ្រាន់តែជាការណែនាំ** ហើយសហគមន៍មានសិទ្ធិក្នុងការបង្កើតឯកសារផ្ទាល់ខ្លួនរបស់ពួកគេ ដែលនេះត្រូវអមដោយការយល់ព្រមរបស់អាជ្ញាធរក្នុងការទទួលឯកសារដែលមានទម្រង់ផ្សេងៗគ្នា។

នៅក្រោមក្រមបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិអាចធ្វើការលុបចោលកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ប្រសិនបើសហគមន៍បរាជ័យក្នុងការអនុវត្តយ៉ាងតឹងរ៉ឹងតាមផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។[17] ការលុបចោលនេះប្រហែលជាធ្វើឡើងក្រោយពេលដែលអាជ្ញាធរថ្នាក់ក្រោមជាតិបានពិនិត្យ និងវាយតម្លៃប្រតិបត្ត

[17] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧១

ការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។[18] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលគួរតែបញ្ជាក់បន្ថែមពី**ការលុបសហគមន៍តំបន់ការពារធម្មជាតិ** ដោយបង្ហាញពីមូលហេតុ និងលក្ខខណ្ឌដែលសហគមន៍តំបន់ការពារធម្មជាតិដែលបានបង្កើតហើយអាចត្រូវបានបញ្ឈប់ ហើយតម្រូវឲ្យមានការផ្តល់ហេតុផលច្បាស់លាស់សម្រាប់ការបញ្ឈប់។ គោលការណ៍ណែនាំស្តីពីការបង្កើតសហ-គមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលគួរតែដាក់បញ្ចូលយន្តការដែលមានសម្រាប់សហគមន៍តំបន់ការពារធម្មជាតិក្នុងការជំទាស់សេចក្តីសម្រេចចិត្តបញ្ចប់សហគមន៍ ដូចជាយន្តការបណ្តឹងសារទុក្ខ។ សហគមន៍តំបន់ការពារធម្មជាតិគួរតែទទួលបានការសងជំងឺចិត្ត ប្រសិនបើការលុបសហគមន៍តំបន់ការពារធម្មជាតិមិនមែនកើតឡើងដោយសារតែជាកំហុសរបស់សហគមន៍ (ក៏ប៉ុន្តែ ជាឧទាហរណ៍ ដោយសារតែមូលហេតុខាងក្រៅ)។

**តម្លាភាព**នៃដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិអាចធ្វើឲ្យប្រសើរឡើង។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល គួរតែធ្វើឲ្យមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានទាក់ទងនឹងដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឧទាហរណ៍ដូចជាបណ្តាលឲ្យសហគមន៍អាចដឹងពីស្ថានភាពនៃដំណើរស្នើសុំរបស់ពួកគេ ហើយក៏អាចផ្តល់នូវយន្តការសម្រាប់អ្នកដែលចាប់អារម្មណ៍ក្នុងការផ្តល់យោបល់ ឬបញ្ចេញការជំទាស់។

**ការយល់ព្រមដោយសេរី ជាមុន និងយល់ព្រមដែលទទួលបានព័ត៌មាន (គោលការណ៍អេហ្វពិក)** របស់ជនជាតិដើមភាគតិច និងសហគមន៍ជិតខាង បច្ចុប្បន្នមិនត្រូវបានបញ្ចូលនៅក្នុងផ្នែកណាមួយនៃយន្តការសហគមន៍តំបន់ការពារធម្មជាតិនោះទេ (ការបង្កើត ការបញ្ចប់ ការបន្ត ការកែប្រែ ជាដើម) ហើយក៏មិនបានតម្រូវឲ្យមានការផ្តល់ជាសំណងខូចខាតដល់ជនជាតិដើមភាគតិច និងសហគមន៍ជិតខាង ប្រសិនបើពួកគេទទួលរងការប៉ះពាល់ដោយលក្ខណៈណាមួយ។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល គួរតែបញ្ចូលយន្តការទាំងនោះជាលក្ខខណ្ឌនៃការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីផ្តល់ការការពារប្រកបដោយបរិយាបន្ន។ ជាឧទាហរណ៍ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចដាក់បញ្ចូលគោលការណ៍អេហ្វពិកជាផ្នែកមួយនៃជំហានទី១ នៃដំណើរការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលក៏អាចផ្តល់ការណែនាំលើវិធីសាស្ត្រក្នុងការបំពេញតម្រូវការអេហ្វពិក នៅក្នុងដំណើរការកំពុងបង្កើតសហ-គមន៍តំបន់ការពារធម្មជាតិ។

[18] *មើល*ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧១



## គោលការណ៍ទី ៣៖ ការបង្កើតច្បាប់លើការគ្រប់គ្រងព្រៃសហគមន៍



ក្របខណ្ឌច្បាប់គួរតែផ្តល់សិទ្ធិដល់សហគមន៍ក្នុងការបង្កើតផែនការគ្រប់គ្រងព្រៃឈើដែលងាយស្រួល តែល្អិតល្អន់ ដែលយោងតាមគំរូដែលងាយស្រួលយល់។ ច្បាប់គួរតែតាក់តែងឡើងដើម្បីឲ្យផែនការគ្រប់គ្រងនេះអាចធ្វើការកែប្រែតាមកាលៈទេសៈក្នុងតំបន់ ដូចជាប្រភេទនៃសកម្មភាពដែលរំពឹងទុកនៅក្នុងព្រៃ ទំហំដីព្រៃ និងទំហំសហគមន៍។

3.1 ក្របខណ្ឌច្បាប់គិតគូរពីការបង្កើតផែនការគ្រប់គ្រងរយៈពេលវែង ដែលឆ្លុះបញ្ចាំងពីចក្ខុវិស័យរបស់សហគមន៍ទាំងមូល ក៏ដូចជាផែនការការងាររយៈពេលខ្លី (ដែលស្របតាមផែនការគ្រប់គ្រងរយៈពេកវែង) ដើម្បីផ្តល់នូវភាពបត់បែនក្នុងការធ្វើផែនការ និងការអនុវត្តសកម្មភាពមួយចំនួន។ តម្រូវការសម្រាប់ផែនការគ្រប់គ្រងទាំងពីរប្រភេទគួរតែមានភាពងាយស្រួលគ្រប់គ្រាន់សម្រាប់សហគមន៍ក្នុងការបង្កើតឡើងដោយខ្លួនឯង។

3.2 ក្របខណ្ឌច្បាប់គួរតែបញ្ជាក់យ៉ាងច្បាស់ថាតើសកម្មភាពអ្វីខ្លះដែលត្រូវបានអនុញ្ញាត ឬហាមឃាត់នៅក្នុងតំបន់ព្រៃសហគមន៍ ដើម្បីជាការណែនាំដល់ការរចនា និងការអនុវត្តផែនការគ្រប់គ្រង។

3.3 ប្រភេទនៃស្ថាប័នសហគមន៍ដែលទទួលខុសត្រូវសម្រាប់ការបង្កើត ការអនុម័ត និងការអនុវត្តផែនការគ្រប់គ្រងគួរតែត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងក្របខណ្ឌច្បាប់ ព្រមទាំងតំណាងឲ្យផ្នែកទាំងអស់នៃសហគមន៍ដោយស្មើភាព។ បន្ថែមពីនេះ ដំណើរការបង្កើតផែនការគ្រប់គ្រងគួរតែមានលក្ខណៈជាការចូលរួម។

3.4 បញ្ញត្តិច្បាប់ និងផែនការគ្រប់គ្រងគួរតែត្រូវបានបំពេញបន្ថែមដោយគោលការណ៍ណែនាំ និងគំរូដែលងាយស្រួលទទួលបាន ដើម្បីពន្យល់ពីដំណើរការ និងខ្លឹមសារនៃផែនការគ្រប់គ្រងក្នុងន័យសាមញ្ញ និងគាំទ្រដល់សហគមន៍ក្នុងការបង្កើតផែនការដោយខ្លួនឯង។

3.5 ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យមានការគាំទ្រពីខាងក្រៅដល់សហគមន៍ក្នុងការបង្កើតផែនការគ្រប់គ្រង និងសម្រាប់សកម្មភាពពង្រឹងសមត្ថភាពសហគមន៍ ក៏ដូចជាអាជ្ញាធរមូលដ្ឋាន។

3.6 ក្របខណ្ឌច្បាប់គួរតែកំណត់អាជ្ញាធរទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តនៃផែនការគ្រប់គ្រង ក៏ដូចជាតម្រូវការរាយកាណ៍របស់សហគមន៍។

## ការវាយតម្លៃ

ក្រុមបរិស្ថានរំពឹងថាការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិនឹងត្រូវបានពិនិត្យឡើងវិញរៀងរាល់ ៣ឆ្នាំម្តង (ឬរយៈពេលមុននៅក្នុងករណីពិសេស)។[19] កំណែប្រែគោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិគួរតែដាក់បញ្ចូលថាផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមាន**សុពលភាពរយៈពេល ៣ឆ្នាំ** (បច្ចុប្បន្ន សុពលភាពនៃផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិនៅក្រោមគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិគឺរយៈពេល ៥ឆ្នាំ[20])។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឆ្នាំ២០១៧ក៏បានលើកឡើងអំពី "**ផែនការសកម្មភាពប្រចាំឆ្នាំ**" ដែលតម្រូវជាផ្នែកមួយនៃការព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ[21] ក៏ប៉ុន្តែគោលការណ៍ណែនាំនេះមិនបានបញ្ជាក់លម្អិតបន្ថែមពីផែនការសកម្មភាពប្រចាំឆ្នាំនេះទេ។ គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួល គួរតែបញ្ជាក់ឲ្យច្បាស់ពីការបង្កើតផែនការសកម្មភាពប្រចាំឆ្នាំ។ ឧទាហរណ៍ បច្ចុប្បន្នផែនការសកម្មភាពប្រចាំឆ្នាំនេះហាក់ដូចជាត្រូវបានយល់ដឹងថាជាការបំបែកផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិទៅជាច្រើនឆ្នាំ (ដូចជា សកម្មភាពដែលរំពឹងទុកសម្រាប់ឆ្នាំទី១ ឆ្នាំទី២ ជាដើម) ក៏ប៉ុន្តែវិធីសាស្ត្រដែលប្រសើរជាងនេះគឺសហ-គមន៍ត្រូវធ្វើផែនការសកម្មភាពនេះជារៀងរាល់ឆ្នាំ។ បើទោះបីជាផែនការសកម្មភាពប្រចាំឆ្នាំនៅតែជាផ្នែកមួយនៃផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ការធ្វើផែនការសកម្មភាពមួយឆ្នាំម្តងនឹងអនុញ្ញាតឲ្យមានភាពបត់បែនក្នុងការធ្វើផែនការ និងការអនុវត្តសកម្មភាពមួយចំនួនអាស្រ័យតាមកាលៈទេសៈដែលបានផ្លាស់ប្តូរ។

ដំណើរការបច្ចុប្បន្ននៃការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងតម្រូវការផែនការគ្រប់គ្រងហាក់បីដូចជា**មិនបានរំពឹងថាសហគមន៍នឹងអាចបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដោយខ្លួនឯងបាន** ឬគិតថាផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិអាចមានភាពងាយស្រួល។ ការគាំទ្រ និងការចូលរួមពីភាគីខាងក្រៅ (អាជ្ញាធររដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា) ត្រូវបានចែងទុកនៅក្នុងដំណើរការបង្កើត រួមទាំងមានបញ្ជាក់ពីជំហាននីមួយៗសម្រាប់ការធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធលើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិផងដែរ។[22] គំរូសម្រាប់ការសរសេរផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ដែលផ្តល់នៅក្នុងឧបសម្ព័ន្ធសបញ្ជាក់ថាការធ្វើផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិគឺជាការងារដ៏សន្លឹកសន្ធាប់។[23] កិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិក៏ហាក់ដូចជាតម្រូវឲ្យមាន

[19] ក្រុមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧៤

[20] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ២៦

[21] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៦.៤

[22] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ២៥; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ, ជំពូក ៦.១-៦.៧ (ជំហាននៃការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ)

[23] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៤ (គំរូសម្រាប់ការសរសេរផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ)

ការគាំទ្រផ្នែកបច្ចេកទេស និងធនធានពីអាជ្ញាធររដ្ឋាភិបាល ដូចជាមានខ្លឹមសារខ្លះទាក់ទងនឹងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។[24]

គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួលអាចអនុញ្ញាតឲ្យសហគមន៍**ដឹកនាំការតាក់តែងផែនការគ្រប់គ្រងដែលសាមញ្ញ សមស្របតាមសមត្ថភាពរបស់សហគមន៍ និងសមស្របតាមកាលៈទេសៈគ្រប់បែបយ៉ាង** យោងតាមប្រភេទនៃសកម្មភាពដែលបានលើកឡើង ទំហំរបស់សហ-គមន៍ និងទំហំផ្ទៃដីរបស់សហគមន៍តំបន់ការពារធម្មជាតិ។ នេះអាចជួយសម្រួលដល់បញ្ហាប្រឈមដែលសហគមន៍កំពុងជួបប្រទះពាក់ព័ន្ធទៅនឹងតម្រូវការដ៏ស្មុគស្មាញនៅក្នុងផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្ន ព្រមទាំងធានាថាផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិឆ្លុះបញ្ចាំងតថៈភាពជាក់ស្តែងនៃរបៀបដែលសហគមន៍ប្រើប្រាស់ព្រៃឈើ និងធនធានធម្មជាតិ។ គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានសម្រួលអាចសម្រាយលើរចនាសម្ព័ន្ធ និងខ្លឹមសារនៃផែនការគ្រប់គ្រង (ជាពិសេសឯកសារសង្ខេបដែលមានខ្លឹមសារបច្ចេកទេសសមស្របទៅនឹងសមត្ថភាពសហគមន៍ និងសកម្មភាពដែលបានដាក់ស្នើរ) ក៏ដូចជាផ្តល់ភាពបត់បែនដល់ទម្រង់ និងខ្លឹមសាររបស់ផែនការគ្រប់គ្រងផងដែរ។ លើសពីនេះទៅទៀត ការគាំទ្រពីភាគីខាងក្រៅគួរតែបន្តជាជម្រើសសម្រាប់សហគមន៍ បើទោះបីជាឯកសារបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិមានលក្ខណៈសាមញ្ញសម្រាប់សហគមន៍ក្នុងការតាក់តែងឡើងដោយខ្លួនឯងក៏ដោយ។

គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានសម្រួលក៏គួរតែធានាថាអង្គភាពរបស់សហ-គមន៍តំបន់ការពារធម្មជាតិ (បច្ចុប្បន្ន ជាគណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិ) ដែលមានតួនាទីជាចំបងក្នុងការបង្កើត និងអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ **តំណាងឲ្យគ្រប់ផ្នែកទាំងអស់នៃសហគមន៍** ហើយដំណើរការបង្កើតផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិគឺ**មានការចូលរួម** (ដែលផ្តល់ជាអាទិភាពដល់ការចូលរួមរបស់សហគមន៍)។

គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួល គួរតែបញ្ជាក់ពី**សកម្មភាពដែលអនុញ្ញាត និងសកម្មភាពដែលហាមឃាត់**នៅក្នុងតំបន់សហគមន៍តំបន់ការពារធម្មជាតិ ដែលនឹងអាចជាជំនួយដល់ការបង្កើត និងការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។ នេះអាចរួមបញ្ចូលទាំងសកម្មភាពដែលអនុញ្ញាត និងសកម្មភាពដែលហាមឃាត់ដែលបានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត ដូចជាក្នុងក្រមបរិស្ថាន។[25] ការអនុវត្តជីវភាពរបស់ជនជាតិដើមភាគតិចគួរតែទទួលស្គាល់ និងអនុញ្ញាតដោយស្របច្បាប់នៅក្នុងគោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួល (ឧទាហរណ៍ ការប្រើប្រាស់ដីក្នុងតំបន់ចម្រុះដោយជនជាតិដើមភាគតិច ដែលពួកគេបានរួមបញ្ចូលការប្រើប្រាស់ដីសម្រាប់ផលិតកម្មទៅក្នុងទេសភាពព្រៃឈើ)។

គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួលគួរតែ**ផ្តល់សិទ្ធិគ្រប់គ្រងបន្ថែម**ដល់សហគមន៍។ សហគមន៍គួរតែទទួលបានសិទ្ធិក្នុងការចុះកិច្ចសន្យាជាមួយភាគីទីបី ដូចជាក្រុមហ៊ុនឯកជន និងអង្គភាពផ្តល់ហិរញ្ញប្បទាន; សិទ្ធិក្នុងការគ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម; និងសិទ្ធិក្នុងការចូលរួមក្នុងដំណើរការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព (ជាជាងការដាក់កម្រិតការគ្រប់គ្រងឲ្យនៅតែក្នុងសហគមន៍តំបន់ការពារធម្មជាតិ)។

[24] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ៣១; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ, ជំពូក ៧.១-៧.២ (ជំហានក្នុងការរៀបចំកិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ); គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៥ (គំរូកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ)

[25] *ឧ.* ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៥២, ៣៧២, ៣៨៣-៣៨៦

គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួល គួរតែ**បញ្ជាក់យ៉ាងច្បាស់ពីអាជ្ញាធរដែលទទួលខុសត្រូវ**ក្នុងការត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ក្នុងករណីដែលមានការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ន។ គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិដែលបានកែសម្រួលនេះផងដែរ ក៏គួរតែបញ្ជាក់បន្ថែមពី**តម្រូវការរបាយការណ៍**របស់សហគមន៍តំបន់ការពារធម្មជាតិ។ នៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្ន សហគមន៍មានតួនាទីបញ្ជូនរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំទៅអាជ្ញាធររដ្ឋាភិ-បាលផ្សេងៗ។[26]

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិឆ្នាំ២០១៧ ក៏បានផ្តល់**ក្របខណ្ឌសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ។**[27] ការអនុវត្តការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយផ្អែកលើលក្ខខណ្ឌចំនួន៤ ដែលមានភ្ជាប់ជាមួយលក្ខណៈវិនិច្ឆ័យ។ លក្ខខណ្ឌទី៤ផ្តោតលើការគាំទ្រពីខាងក្រៅ ហើយលក្ខខណ្ឌនេះផ្តោតទៅលើការគាំទ្រដែល*ផ្តល់*ឲ្យសហគមន៍ ជាជាងសកម្មភាពរបស់សហគមន៍តំបន់ការពារធម្មជាតិ។ ជាហេតុ លក្ខខណ្ឌនេះអាចត្រួតពិនិត្យនិងវាយតម្លៃមិនត្រឹមតែដោយសហគមន៍នោះទេ ក៏ប៉ុន្តែដោយអាជ្ញាធរពាក់ព័ន្ធដែលអាចដោះស្រាយបញ្ហាពាក់ព័ន្ធនឹងលក្ខខណ្ឌនេះផងដែរ។

[26] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ២១; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៨.៣; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៧ (គំរូរបាយការណ៍ត្រីមាស)

[27] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៨.១-៨.៣; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៦ (គំរូក្របខណ្ឌសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ)



# គោលការណ៍ទី៤៖ គាំទ្រអភិបាលកិច្ចផ្ទៃក្នុងរបស់សហគមន៍



ក្របខណ្ឌច្បាប់គួរតែគាំទ្រអភិបាលកិច្ចផ្ទៃក្នុងរបស់សហគមន៍ ដោយផ្តល់នូវគោលការណ៍ទូទៅសម្រាប់គណនេយ្យភាព និងតម្លាភាពក្នុងការអនុវត្តព្រៃសហគមន៍ ខណៈពេលដែលអនុញ្ញាតឲ្យសហគមន៍បង្កើតយន្តការជាក់លាក់ណាមួយសម្រាប់អនុវត្តគោលការណ៍ទាំងនេះ និងស្របតាមរចនាសម្ព័ន្ធស្ថាប័នរបស់ពួកគេ។

4.1 ក្របខណ្ឌច្បាប់គួរតែធានាថាសហគមន៍សិទ្ធិធ្វើការសម្រេចចិត្តលើរបៀបគ្រប់គ្រងតំបន់ព្រៃសហគមន៍សមស្របតាមអភិបាលកិច្ចផ្ទៃក្នុងរបស់សហគមន៍។

4.2 ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យសហគមន៍អាចបង្កើតអង្គភាពដែលធ្វើសេចក្តីសម្រេចចិត្ត ឬពឹងផ្អែកលើអង្គភាពដែលមានស្រាប់ក្នុងការគ្រប់គ្រងតំបន់ព្រៃសហគមន៍។ អង្គភាពទាំងនោះគួរតែមានគោលដៅ តួនាទី និងការទទួលខុសត្រូវច្បាប់លាស់។

4.3 ទោះបីជាក្របខណ្ឌច្បាប់ផ្តល់ជាយោបល់ ឧទាហរណ៍ ឬគោលការណ៍ណែនាំ សហគមន៍គួរតែត្រូវបានអនុញ្ញាតឲ្យរៀបចំរចនាសម្ព័ន្ធ និងបង្កើតវិន័យ ឬគោលនយោបាយផ្ទៃក្នុង ដូចជាលក្ខន្តិកៈ។ ដើម្បីធ្វើបែបនេះ ក្របខណ្ឌច្បាប់គួរតែទទួលស្គាល់ទំនៀមទំលាប់ និងប្រពៃណីក្នុងស្រុក។

4.4 ក្របខណ្ឌច្បាប់គួរតែបង្កើតជាគោលការណ៍ថាសហគមន៍គួរតែប្រើប្រាស់យន្តការចែករំលែកព័ត៌មាន ជាពិសេសសម្រាប់អ្នកដែលមានតួនាទីដឹកនាំ ដែលព័ត៌មានទាក់ទងនឹងការសម្រេចចិត្ត និងសកម្មភាពក្នុងព្រៃសហគមន៍ ត្រូវបានចែករំលែកយ៉ាងទូលំទូលាយជាមួយសមាជិកសហគមន៍។

4.5 ក្របខណ្ឌច្បាប់គួរតែតម្រូវឲ្យសហគមន៍បង្កើត និងប្រើប្រាស់យន្តការគណនេយ្យភាព ដើម្បីធានាអភិបាលកិច្ចល្អ។ ក្របខណ្ឌច្បាប់គួរតែផ្តល់យន្តការបណ្តឹងជាដំណោះស្រាយផងដែរ។

# ការវាយតម្លៃ

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចធានាថាសហគមន៍មាន**សិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្ត** ទាក់ទងនឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិរបស់ពួកគេ ដោយយោងតាមអភិបាលកិច្ចផ្ទៃក្នុងរបស់សហគមន៍ពួកគេ។ គំរូអភិបាលកិច្ចរបស់សហគមន៍តំបន់ការពារធម្មជាតិមួយមិនអាចប្រើប្រាស់បានគ្រប់កាលៈទេសៈនោះទេ។ សហគមន៍មូលដ្ឋានអាចមានថាមវន្តសង្គមខុសៗគ្នា និងមានរចនាសម្ព័ន្ធអភិបាលផ្ទៃក្នុងខុសគ្នាផងដែរ ដូចនេះការទទួលយក**អភិក្រមដោះស្រាយតាមករណីនីមួយៗ** អាចនឹងមានប្រសិទ្ធិភាព និងសមស្របសម្រាប់អភិបាលកិច្ចផ្ទៃក្នុងរបស់សហគមន៍តំបន់ការពារធម្មជាតិ។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអនុញ្ញាតឲ្យសហគមន៍បង្កើតអង្គភាពដែលមានអំណាចក្នុងការធ្វើសេចក្តីសម្រេច ឬពឹងផ្អែកលើអង្គភាពដែលមានស្រាប់ក្នុងការគ្រប់គ្រងក្នុងការអនុវត្តសហគមន៍តំបន់ការពារធម្មជាតិ។ ដោយផ្តល់នូវភាពបត់បែនដល់**អង្គភាពដែលធ្វើសេចក្តីសម្រេចចិត្ត** គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចជួយក្នុងការកំណត់នូវគោលបំណង តួនាទី និងទំនួលខុសត្រូវ។

ប្រសិនបើគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល រក្សានូវបញ្ជីលក្ខណៈវិនិច្ឆ័យសម្រាប់**បេក្ខភាពគណកម្មការសហគមន៍តំបន់ការពារធម្មជាតិ**[28] លក្ខណៈវិនិច្ឆ័យទាំងនោះត្រូវតែពិនិត្យឡើងវិញដើម្បីបញ្ជាក់ថាវាមិនហួសពីដែនកំណត់។ ជាក់ស្តែង បច្ចុប្បន្នសមត្ថភាពក្នុងការអាន និងសសេរជាភាសាខ្មែរ និង "មានសុខភាពល្អ" ត្រូវបានរាយជាលក្ខណៈវិនិច្ឆ័យចំនួនពី២។ តើតម្រូវការនៃការអាន និងសសេរជាភាសាខ្មែរ អាចរារាំងអ្នកដែលមិនមានសមត្ថភាពនេះក្នុងការចូលរួមជាសមាជិកនៃគណកម្មការសហគមន៍តំបន់ការពារធម្មជាតិដែរឬទេ? តើការដែលមាន "សុខភាពល្អ"ត្រូវបានកំណត់បែបណា ហើយតើអ្នកដែលមានពិការភាពអាចក្លាយជាបេក្ខជនឬទេ?

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអនុញ្ញាតសហគមន៍ឲ្យរៀបចំរចនាសម្ព័ន្ធ និងបង្កើត**វិន័យ/គោលនយោបាយផ្ទៃក្នុង**ដោយខ្លួនឯង ដូចជាលក្ខន្តិកៈសហគមន៍ ហើយស្របពេលជាមួយគ្នានោះបាន**ទទួលស្គាល់នូវទំនៀមទម្លាប់ និងប្រពៃណីមូលដ្ឋាន**។ បច្ចុប្បន្ន ការបង្កើតលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិគឺជាតម្រូវការ។ ដំណើរការនៃការបង្កើតលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិមានជាច្រើនជំហាន ហើយគំរូនៃលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិក៏ត្រូវបានផ្តល់ផងដែរ។[29] ការប្រឹក្សាយោបល់ជាមួយភាគីខាងក្រៅគឺជាការតម្រូវក្នុងការតាក់តែងលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ហើយអាជ្ញាធររដ្ឋាភិបាល ហើយអាជ្ញាធររដ្ឋា-ភិបាលហាក់បីដូចជាអាចធ្វើការកែប្រែលើលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ ដែលបានដាក់ស្នើ។[30] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចធានាថាសហគមន៍មាន**ភាពជាម្ចាស់ការ**លើការបង្កើត និងខ្លឹមសារនៃលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិដែលពួកគេបានសម្រេច។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់ថា**យន្តការចែករំលែកព័ត៌មាន**គួរតែប្រើប្រាស់ដោយសហគមន៍តំបន់ការពារធម្មជាតិ ជាពិសេសសម្រាប់អ្នកដែលមានតួនាទីជាអ្នកដឹកនាំ ដោយសារតែ

[28] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៣.១

[29] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៥.១-៥.៥; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៣

[30] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៥.៤

ពួកគេជាអ្នកចែករំលែកព័ត៌មានទាក់ទងនឹងសេចក្តីសម្រេចចិត្ត សកម្មភាព -ល-របស់សហគមន៍តំបន់ការពារធម្មជាតិយ៉ាងទូលំទូលាយដល់សមាជិកសហគមន៍តំបន់ការពារធម្មជាតិ។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចតម្រូវឲ្យសហគមន៍តាក់តែង និងប្រើប្រាស់**យន្តការគណេយ្យភាព** ក្នុងបំណងធានានូវអភិបាលកិច្ចល្អ ជាឧទាហរណ៍ រៀបចំកិច្ចប្រជុំទៀងទាត់ជាមួយសមាជិកសហគមន៍ ធ្វើការរាយការណ៍ហិរញ្ញវត្ថុជាដើម។ល។ ការកែសម្រួលនៃគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ក៏អាចពិចារណាជារួមទៅលើបញ្ញត្តិស្តីពី**យន្តការបណ្តឹងទាមទារដំណោះស្រាយ**។ បច្ចុប្បន្ននេះ ការទាមទារដំណោះស្រាយមានតែជម្រើសមួយប៉ុណ្ណោះគឺការបញ្ឈប់គណៈកម្មាការសហគមន៍តំបន់ការពារធម្មជាតិ ហើយការបោះឆ្នោតថ្មីមួយនឹងត្រូវបានរៀបចំឡើង ប្រសិនបើ៦០%នៃសមាជិកសហគមន៍តំបន់ការពារធម្មជាតិស្នើសុំអន្តរាគមន៍ពីក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីដោះស្រាយការគ្រប់គ្រងមិនល្អរបស់គណកម្មការសហគមន៍តំបន់ការពារធម្មជាតិ។[31]

[31] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ១៧; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៣



## គោលការណ៍៥៖ អនុញ្ញាតឲ្យមានការចូលរួមពីសហគមន៍ និងការតំណាងក្រុមភាគតិច



ក្របខណ្ឌច្បាប់គួរជម្រុញព្រៃសហគមន៍ដោយដាក់បញ្ចូលបញ្ញត្តិជាក់លាក់ ដើម្បីធានាការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត សកម្មភាព និងការគ្រប់គ្រងនៅក្នុងព្រៃសហគមន៍ ដោយសមាជិកសហគមន៍ ជាពិសេសក្រុមភាគតិច ដូចជាស្ត្រី ជនជាតិដើមភាគតិច ជនជាតិភាគតិច និងសមាជិកដែលជួបភាពក្រីក្រ ឬមានអំណាចតិចបំផុតនៅក្នុងសហគមន៍ ដោយផ្អែកលើបរិបទមូលដ្ឋាន។ ការចូលរួមរបស់យុវជនក៏គួរតែត្រូវបានលើកទឹកចិត្តផងដែរ។ ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតសមាជិកសហគមន៍ក្នុងការកំណត់យន្តការសមស្របក្នុងការចូលរួមចំណែក។

5.1 ក្របខណ្ឌច្បាប់គួររួមបញ្ចូលនូវបញ្ញត្តិទាក់ទងនឹងការរួមបញ្ចូលក្រុមភាគតិចក្នុងព្រៃសហគមន៍ ដែលអាចមានភាពខុសគ្នាអាស្រ័យទៅនឹងបរិបទក្នុងមូលដ្ឋាននៃប្រទេសនីមួយៗ។ ក្រុមទាំងនោះរួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែស្ត្រី ជនជាតិដើមភាគតិច ជនជាតិភាគតិច និងសមាជិកដែលជួបភាពក្រីក្រ និងក្រុមដែលត្រូវបានផាត់ចេញពីសង្គម។

5.2 ក្របខណ្ឌច្បាប់គួរតែបញ្ជាក់ឲ្យច្បាស់ពីក្រុមភាគតិចដែលជាក្រុមគោលដៅសម្រាប់ការបង្កើនការចូលរួមរបស់ពួកគេ។

5.3 ក្របខណ្ឌច្បាប់គួរតម្រូវឲ្យការចូលរួមក្នុងការសម្រេចចិត្ត ហើយដែលក្រុមភាគតិចអាចចូលរួមបានយ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព និង/ឬត្រូវតំណាងបានយ៉ាងត្រឹមត្រូវ។ ដើម្បីធានាបាននូវការចូលរួមយ៉ាងសំខាន់ ក្របខណ្ឌច្បាប់គួរតែតម្រូវឲ្យមានតំណាងនៃក្រុមភាគតិចនៅក្នុងការសម្រេចចិត្តគ្រប់កម្រិត រួមទាំងក្នុងតួនាទីជាអ្នកដឹកនាំផងដែរ។

5.4 ក្របខណ្ឌច្បាប់គួរលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងព្រៃសហគមន៍។

5.5 ក្របខណ្ឌច្បាប់គួរតែអនុញ្ញាត និងលើកទឹកចិត្តតាមការចាំបាច់ នូវការគាំទ្រពីខាងក្រៅដល់សហគមន៍ដើម្បីជួយជំរុញឲ្យមានការចូលរួមកាន់តែច្រើនឡើងដោយក្រុមភាគតិច និងយុវជន ដូចជាដោយតែងតាំងអ្នកសម្របសម្រួលសហគមន៍។

## ការវាយតម្លៃ

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាច**ពង្រីកការរួមបញ្ចូលរបស់ក្រុមភាគតិច**ក្នុងការសម្រេចចិត្ត ការគ្រប់គ្រង និងសកម្មភាពរបស់សហគមន៍តំបន់ការពារធម្មជាតិ។ ការចូលរួមរបស់ស្ត្រីត្រូវបានសង្កត់ធ្ងន់យ៉ាងជាក់ច្បាស់ (*ឧទាហរណ៍* ការលើកកម្ពស់ស្ត្រីឲ្យក្លាយជាផ្នែកមួយនៃរចនាសម្ព័ន្ធគ្រប់គ្រង ការចូលរួមរបស់ស្ត្រីក្នុងការតាក់តែងលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ)។[32] មិនមានក្រុមភាគតិចណាផ្សេងទៀតដែលត្រូវបានលើកឡើងក្រៅពីស្ត្រីនោះទេ សមាជិកភាគតិចផ្សេងទៀតគួរតែទទួលបានការយកចិត្តទុកដាក់ដូចជា អ្នកដែលជួបភាពក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច ស្ត្រីមេម៉ាយ ជាដើម។ល។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់បន្ថែមពីក្រុមភាគតិចដែលជាក្រុមគោលដៅ ដើម្បីលើកកម្ពស់ការចូលរួមរបស់ពួកគេ។

ដើម្បីធានាការចូលរួមក្នុងការសម្រេចចិត្ត គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចតម្រូវអោយមាន**តំណាងនៃក្រុមភាគតិចនៅគ្រប់កម្រិតនៃការសម្រេចចិត្ត** រួមទាំងក្នុងតួនាទីជាអ្នកដឹកនាំផងដែរ។ នេះអាចអនុញ្ញាតឲ្យក្រុមភាគតិចធ្វើការចូលរួមយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធិភាព និង/ឬត្រូវតំណាងបានយ៉ាងត្រឹមត្រូវ។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ក៏អាចលើកកម្ពស់**ការចូលរួមរបស់យុវជន** ទាំងកុមារី និងកុមារា។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ក៏អាចបញ្ជាក់ពីនិយមន័យនៃ "**សមាជិកសហគមន៍តំបន់ការពារធម្មជាតិ**" ដោយសារតែកង្វះនិយមន័យអាចនឹងមានផលប៉ះពាល់ដល់ការចូលរួមរបស់ក្រុមភាគតិច។ ក្រោមគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្ន សមាជិកសហគមន៍តំបន់ការពារធម្មជាតិគឺចុះឈ្មោះជាគ្រួសារ ដោយមានមេគ្រួសារជាតំណាងនៃសមាជិកសហគមន៍តំបន់ការពារធម្មជាតិ។[33] ជាលទ្ធផលមេគ្រួសារ គឺជាមនុស្សតែមួយគត់ដែលអាចចូលរួមក្នុងសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងសហគមន៍តំបន់ការពារធម្មជាតិ ហើយវានឹងក្លាយជាបញ្ហានៅពេលមេគ្រួសារមិនអាចតំណាងបានយ៉ាងសមស្របនូវទស្សនៈរបស់សមាជិកគ្រួសារ។ ដើម្បីអនុញ្ញាតអោយមានការចូលរួម និងតំណាងប្រកបដោយបរិយាប័ន្ន គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចកំណត់ "សមាជិកសហគមន៍តំបន់ការពារធម្មជាតិ" ជាបុគ្គលដែលជាផ្នែកមួយនៃសហគមន៍ ចៀសជាងកំណត់សមាជិកភាពសហគមន៍តំបន់ការពារធម្មជាតិនៅក្នុងកម្រិតគ្រួសារ។

[32] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ១៣; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៣.២, ៣.៣, ៥.២; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៣

[33] *មើល*គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ១០ (សមាជិកភាពនៃសហគមន៍តំបន់ការពារធម្មជាតិ គឺត្រូវបានធ្វើឡើងដោយការចុះឈ្មោះជាគ្រួសារ), ១១ (សហគមន៍តំបន់ការពារធម្មជាតិមិនអាចបង្កើតឡើងបានឡើយ លុះត្រាតែមានការចូលរួមដោយស្ម័គ្រចិត្តពីយ៉ាងតិច ៦០%នៃចំនួន*គ្រួសារ*ទាំងអស់ក្នុងភូមិ) (មានការសង្កត់ធ្ងន់), ១៥ (មេគ្រួសារដែលត្រូវបានចុះឈ្មោះជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិអាចបោះឆ្នោតបាន ប្រសិនបើមានអាយុយ៉ាងតិច ១៨ឆ្នាំ); គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ១ (គំរូលិខិតសុំចូលសមាជិកសហគមន៍តំបន់ការពារធម្មជាតិ)

វាអាចជាផលប្រយោជន៍មួយផងដែរសម្រាប់គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ក្នុងការមិនសន្មត់ថាសមាជិកសហគមន៍តំបន់ការពារធម្មជាតិបាន**យល់ព្រមដោយស្វ័យប្រវិត្តទៅនឹងផែនការសកម្មភាពនៅពេលដែលពួកគេមិនបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត**។[34] ហេតុនេះអាចបណ្តាលអោយមានលទ្ធផលដែលមិនឆ្លុះបញ្ចាំងការពិត ផ្ទុយទៅវិញការមិនចូលរួមគួរចាត់ទុកជាការជ្រើសយកជំហរអព្យាក្រឹត្យ។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអនុញ្ញាតឲ្យមានការគាំទ្រពីខាងក្រៅដល់សហគមន៍ ដើម្បីជួយជំរុញឲ្យមានការចូលរួមកាន់តែច្រើនឡើងពីក្រុមភាគតិច និងយុវជន ដូចជាដោយការតែងតាំង**អ្នកសម្របសម្រួលសហគមន៍**។

[34] *ឧ.* គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ១៣; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៥.៣ (លក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ), ៦.៥ (ផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ)



## គោលការណ៍៦៖ ការអនុញ្ញាតឲ្យសហគមន៍ទទួលបានទីផ្សារ

ក្របខណ្ឌច្បាប់គួរតែផ្តល់ការគាំទ្រ និងសម្របសម្រួលឱកាសសម្រាប់ការទទួលបានទីផ្សារ និងការលក់ផលិតផល និងសេវាព្រៃសហគមន៍ដោយមានបទប្បញ្ញត្តិអនុញ្ញាតដែលជាក់ច្បាស់លាស់ លើពន្ធ ការដឹកជញ្ជូន និងកែឆ្នៃ ព្រមទាំងការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច។

6.1 ក្របខណ្ឌច្បាប់គួរតែដាក់ចេញនូវច្បាប់សាមញ្ញ ដើម្បីអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ច និងបង្កើតអាជីវកម្មសហគមន៍ ក៏ដូចជាជួយសម្រួលដល់ការចូលទៅកាន់ជំហានផ្សេងៗ ឬថ្នាំងនៃខ្សែសង្វាក់ផ្គត់ផ្គង់សម្រាប់ការផ្តល់ផលិតផល និងសេវាកម្មព្រៃឈើប្រកបដោយចីរភាព។

6.2 ការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចផ្សេងៗគ្នាគួរតែត្រូវបានពិចារណា ដើម្បីជំរុញការទទួលបានទីផ្សាររបស់សហគមន៍ ដូចជាការលើកលែងពន្ធ ការឧបត្ថម្ភធន វិធានសាមញ្ញសម្រាប់ការទទួលបានលិខិតអនុញ្ញាតដឹកជញ្ជូន ឬផលិតកម្ម តម្រូវការលិខិតអនុញ្ញាតផ្សេងៗគ្នាអាស្រ័យលើទំហំសហគ្រាសពាណិជ្ជកម្ម (ឧទាហរណ៍ ពាណិជ្ជកម្មខ្នាតតូចសម្រាប់ប្រមូលដើម្បីទីផ្សារក្នុងស្រុកធៀបនឹងផលិតផលដែលចូលក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ធំ) ឬប្រភេទផលិតផល (ដូចជាឈើធៀបនឹងអនុផលព្រៃឈើ) ភាពកាន់តែងាយស្រួលសម្រាប់សហគ្រាសសហគមន៍ក្នុងការទទួលបានដើមទុន និងជំនួយបច្ចេកទេស។

6.3 ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យសហគមន៍ចុះកិច្ចព្រមព្រៀងជាមួយភាគីទីបីក្នុងការគ្រប់គ្រងព្រៃឈើ រួមទាំងក្រុមហ៊ុន ខណៈផ្តល់ការការពារប្រឆាំងនឹងការរំលោភលើវិសមភាពអំណាចរវាងសហគមន៍ និងភាគីទីបី ព្រមទាំងយន្តការបណ្តឹងសារទុក្ខ។

# ការវាយតម្លៃ

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអនុញ្ញាតសហគមន៍តំបន់ការពារធម្មជាតិ**អភិវឌ្ឍសកម្មភាពសេដ្ឋកិច្ច និងបង្កើតអាជីវកម្មសហគមន៍** ក៏ដូចជាជួយសម្រួលដល់ការចូលរួមនៅក្នុងខ្សែសង្វាក់ផលិតកម្មសម្រាប់ការផ្តល់ផលិតផល និងសេវាកម្មព្រៃឈើ ប្រកបដោយចីរភាព។ **ការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច**ក៏អាចត្រូវបានផ្តល់ជូនផងដែរ ដើម្បីជំរុញការទទួលបានទីផ្សាររបស់សហគមន៍តំបន់ការពារធម្មជាតិ។

សក្តានុពលសម្រាប់សកម្មភាពពាណិជ្ជកម្ម និងកំណើនសេដ្ឋកិច្ច គឺជាកត្តាជំរុញដ៏សំខាន់សម្រាប់ការចូលរួមក្នុងសហគមន៍តំបន់ការពារធម្មជាតិ។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអនុញ្ញាតឲ្យសហគមន៍តំបន់ការពារធម្មជាតិ**គ្រប់គ្រងសកម្មភាពពាណិជ្ជកម្ម និងធ្វើកិច្ចព្រមព្រៀងជាមួយភាគីទីបី** (ដោយផ្តល់នូវយន្តការការពារប្រឆាំងនឹងការរំលោភបំពាននៃវិសមភាពអំណាច ក៏ដូចជាយន្តការបណ្តឹងសារទុក្ខ)។ ដូច្នេះ វាមានភាពចាំបាច់ក្នុង**ការកាត់បន្ថយហានិភ័យ**សម្រាប់សហគមន៍តំបន់ការពារធម្មជាតិដែលស្វែងរកភាពជាដៃគូក្នុងវិស័យឯកជន ដើម្បីការពារគ្រោះថ្នាក់ពួកគេពី**វិសមភាពអំណាច ឬការកាន់កាប់ដោយមនុស្សមួយចំនួនតូច។**

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលក៏អាចផ្តល់ការគាំទ្រ និងការណែនាំសម្រាប់**ពង្រីកផលិតកម្មក្នុងទំហំពាណិជ្ជកម្ម** ក៏ដូចជាលើ**ការបញ្ជាក់ពីភាពត្រឹមត្រូវនៃផលិតផល និងតម្លៃសមរម្យ។**

យ៉ាងណាក្តី ភាពស្មុគស្មាញក្នុងការអនុញ្ញាតឲ្យសហគមន៍ក្នុងការទទួលបានទីផ្សារ តម្រូវឲ្យមានការវិភាគបន្ថែមលើក្រមបរិស្ថានជាពិសេសទាក់ទងទៅនឹង**ការកំណត់អត្តសញ្ញាណច្បាស់លាស់នៃអាជ្ញាធរ ដែលទទួលខុសត្រូវចំពោះទិដ្ឋភាពផ្សេងៗនៃការទទួលបានទីផ្សារ។** យោងតាមក្រមបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារពាក់ព័ន្ធផ្សេងទៀត ក៏ដូចជាការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ធម្មជាតិដោយសហគមន៍មូលដ្ឋាន។[35]

ចំណុចមួយទៀតដែលត្រូវបញ្ជាក់ ហើយដែលអាចប៉ះពាល់ដល់ការកែសម្រួលគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិគឺការបកស្រាយក្រមបរិស្ថានត្រង់ចំណុចដែលចែងថាអាជ្ញាធរថ្នាក់ក្រោមជាតិមិនអាចអនុញ្ញាត (ដរាបណាមានការអនុញ្ញាតពីរដ្ឋាភិបាល) ក្នុងការធ្វើ**ពាណិជ្ជកម្មព្រៃ និងអនុផលព្រៃឈើមិនមែនឈើ សម្រាប់ហេតុផលសេដ្ឋកិច្ចក្នុងតំបន់មូលដ្ឋាន។**[36] ចំណុចនេះ មានភាពមិនច្បាស់លាស់ឡើយថាតើ សហគមន៍តំបន់ការពារធម្មជាតិមិនត្រូវបានអនុញ្ញាតក្នុងការធ្វើសកម្មភាពសេដ្ឋកិច្ច។ លើសពីនេះ វាហាក់បីដូចជាផលិតផល និងអនុផលធនធានធម្មជាតិអាចត្រូវបានកែច្នៃ ហើយមូលដ្ឋានរោងម៉ាស៊ីនអារឈើសម្រាប់កែច្នៃឈើ រោងចក្រកែច្នៃឈើ និងរោងសម្រាប់**កែច្នៃផលិតផលធនធានធម្មជាតិ និងអនុផល**អាចត្រូវបានបង្កើតឡើង និងដំណើរការក្នុងសហគមន៍តំបន់ការពារធម្មជាតិ ប្រសិនជាមានការយល់ព្រមពីក្រសួងបរិស្ថាន។ ទោះបីជាយ៉ាងណាក៏ដោយ វាអាចតម្រូវឲ្យមានការបំភ្លឺ ដោយសារក្រមបរិស្ថានថាសកម្មភាពបែបនេះអាចកើតឡើងនៅក្នុងតំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងតំបន់សហគមន៍ ប្រសិនបើត្រូវបានអនុម័ត (ប៉ុន្តែមិនសំដៅជាពិសេសទៅលើសហគមន៍តំបន់ការពារធម្មជាតិឡើយ)។[37]

[35] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៥២, ៣៧៨

[36] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៥៣

[37] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៨៥

ក្រមបរិស្ថានក៏រំពឹងផងដែរនូវ**ការអភិវឌ្ឍន៍គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិនៃវិធានការសេដ្ឋកិច្ច ដើម្បីគាំទ្រដល់បរិស្ថាន និងធនធានធម្មជាតិ** ដោយការអភិវឌ្ឍន៍នោះ រួមទាំងការពិចារណាលើការគ្រប់គ្រងធនធានធម្មជាតិតាមសហគមន៍ (រួមទាំងការលើកលែងពន្ធលើតម្លៃបន្ថែម និងការយកពន្ធផ្សេងទៀតនៃប្រាក់ចំណូល ថ្លៃសេវា មូលនិធិ ឬ ការរួមចំណែកផ្សេងទៀត ដែលទទួលបានក្នុងដំណើរការនៃការអនុវត្តការគ្រប់គ្រងរួមគ្នា[38]); ការបែងចែកប្រាក់ចំណូលដោយសមធម៌ពីយន្តការលក់កាបូន; និងការបង់ប្រាក់សម្រាប់ការបង្កើត ឬសេវាថែរក្សាធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីដល់បុគ្គល និងសហគមន៍ដែលសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។[39]

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចអនុញ្ញាតសហគមន៍តំបន់ការពារធម្មជាតិ**ទទួលបាន និងគ្រប់គ្រងប្រាក់ដោយផ្ទាល់**ពីការវិនិយោគឯកជន និងសកម្មភាពពាណិជ្ជកម្ម និងប្រភពមូលនិធិសាធារណៈ (*ឧ.* ទេសចរណ៍ធម្មជាតិ ការប្រមូល និងប្រើប្រាស់អនុផលព្រៃឈើមិនមែនឈើ យន្តការហិរញ្ញប្បទានកាបូន ហិរញ្ញប្បទានអភិរក្ស និងមូលនិធិវិនិយោគ ប្រាក់ពីកិច្ចសន្យា ឬការរៀបចំចែករំលែកអត្ថប្រយោជន៍ ជំនួយ មូលនិធិបរិស្ថាន និងសង្គម មូលនិធិឃុំ/សង្កាត់ ប្រភពចំណូលផ្សេងទៀត)។ វិធីសាស្ត្រមួយអាចជាការបង្កើតមូលនិធិ/គណនីសហគមន៍តំបន់ការពារធម្មជាតិសម្រាប់សហគមន៍តំបន់ការពារធម្មជាតិនីមួយៗដែលនឹងត្រូវបានគ្រប់គ្រងដោយសហគមន៍។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចរួមបញ្ចូលការផ្តល់ធនធានរបស់រដ្ឋាភិបាលសម្រាប់**ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ**ដល់សហគមន៍តំបន់ការពារធម្មជាតិ ដើម្បីចាប់ផ្តើមអាជីវកម្មក្នុងតំបន់ ក៏ដូចជា**ការកសាងសមត្ថភាព**សម្រាប់ការគ្រប់គ្រងអាជីវកម្ម និងការអភិវឌ្ឍន៍ផលិតផលប្រកបដោយចីរភាព។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលក៏អាចផ្តល់ការគាំទ្រ ការបង្កើត**សហករ ឬសមាគមអ្នកផលិតក្នុងស្រុក ពាណិជ្ជករ និងអ្នកនាំចេញក្នុង**ចំណោមសហគមន៍ ដើម្បីជំរុញការចែករំលែកធនធាន និងបង្កើនអានុភាពទីផ្សារកាន់តែធំ។

នៅក្រោមគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្ន ការអនុវត្តការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយផ្អែកលើលក្ខខណ្ឌចំនួន៤ ជាមួយនឹងលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធ។ លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌទាំងអស់គឺផ្តោតលើការគាំទ្រពីអ្នកខាងក្រៅ ហើយលក្ខណៈវិនិច្ឆ័យមួយនៃលក្ខខណ្ឌនេះគឺ**ការគាំទ្រសម្រាប់តម្លៃផលិតផលនៅក្នុងទីផ្សារ**។[40] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចពិចារណាបន្ថែមទៀតអំពីរបៀបដែលលក្ខខណ្ឌ/លក្ខណៈវិនិច្ឆ័យសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃនេះអាចត្រូវបានគាំទ្រឲ្យកាន់តែប្រសើរឡើង។

[38] "ការគ្រប់គ្រងរួមគ្នា" មិនត្រូវបានផ្តល់និយមន័យនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិនោះទេ ក៏ប៉ុន្តែវាត្រូវបានយល់ជារួមថាសំដៅលើការសហការទាំងឡាយរវាងរដ្ឋាភិបាល សហគមន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន។ល។ ដែលចូលរួម/ពាក់ព័ន្ធនឹងការការពារ ការអភិរក្ស និង/ឬការគ្រប់គ្រងបរិស្ថាន និង/ឬធនធានធម្មជាតិ។

[39] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៥៩

[40] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ជំពូក ៨.១; គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ, ឧបសម្ព័ន្ធទី ៦ (គំរូក្របខណ្ឌសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ)



## គោលការណ៍៧៖ ការបែងចែកផលប្រយោជន៍ប្រកបដោយសមភាព



ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យមានការចែករំលែកផលប្រយោជន៍ដោយផ្តល់នូវក្របខ័ណ្ឌទូទៅ ខណៈអនុញ្ញាតឲ្យសហគមន៍ប្រើប្រាស់យន្តការផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីចែករំលែកផលប្រយោជន៍ពីសកម្មភាពព្រៃសហគមន៍ប្រកបដោយសមធម៌រវាងសមាជិកសហគមន៍។ ក្របខ័ណ្ឌច្បាប់គួរតែផ្តល់នូវការការពារដែលធានានូវតម្លាភាពព័ត៌មាន និងប្រព័ន្ធត្រួតពិនិត្យមួយ ដើម្បីការពារសមាជិកសហគមន៍ពីហានិភ័យដូចជាការកាន់កាប់ដោយមនុស្សមួយចំនួនតូច។

7.1 ក្របខណ្ឌច្បាប់គួរតែចែងថាអត្ថប្រយោជន៍រូបិយវត្ថុ សម្ភារៈ និងមិនមែនរូបិយវត្ថុ/មិនមែនសម្ភារៈដែលបានមកពីការប្រើប្រាស់ និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍គឺជាកម្មសិទ្ធិរបស់សហគមន៍។

7.2 ក្របខ័ណ្ឌច្បាប់គួរតែរួមបញ្ចូលគោលការណ៍នៃការចែករំលែកអត្ថប្រយោជន៍ដោយសមធម៌ ខណៈពេលដែលទទួលស្គាល់ថាសហគមន៍អាចប្រើប្រាស់យន្តការចែករំលែកអត្ថប្រយោជន៍ជាក់លាក់របស់ពួកគេផ្ទាល់។

7.3 ក្របខ័ណ្ឌច្បាប់អាចផ្តល់ការណែនាំអំពីការបង្កើត និងអនុវត្តយន្តការចែករំលែកអត្ថប្រយោជន៍ដោយឧទាហរណ៍ ការកំណត់ការចែករំលែកអត្ថប្រយោជន៍ (ប្រភេទនៃអត្ថប្រយោជន៍ ការចែករំលែកអត្ថប្រយោជន៍ផ្តេកធៀបនឹងបញ្ឈរ) ឬការផ្តល់ឧទាហរណ៍ ឬគំរូនៃការរៀបចំការចែករំលែកអត្ថប្រយោជន៍។

7.4 ក្របខណ្ឌច្បាប់គួរតែគិតគូរអំពីយន្តការដែលកាត់បន្ថយហានិភ័យនៃការចាប់យកផលប្រយោជន៍ ឬការកាន់កាប់ដោយមនុស្សមួយចំនួនតូច ដូចជាការរៀបចំប្រព័ន្ធដើម្បីធានាតម្លាភាព គណនេយ្យភាព និងការត្រួតពិនិត្យការចែករំលែកអត្ថប្រយោជន៍។ យន្តការដើម្បីធានាការទទួលបានអត្ថប្រយោជន៍ស្មើភាពគ្នាដោយក្រុមភាគតិច ដូចជាស្ត្រី ជនជាតិដើមភាគតិច ជនជាតិភាគតិច និងក្រុមដទៃផ្សេងទៀតក៏គួរតែមានផងដែរ។

# ការវាយតម្លៃ

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចជម្រុញការចែករំលែកផលប្រយោជន៍ប្រកបសមធម៌នៅច្រើនកម្រិត។ ជាឧទាហរណ៍ នៅក្រោមក្រមបរិស្ថាន ក្រសួងបរិស្ថានមានភារកិច្ចបង្កើត**យន្តការសម្រាប់កំណត់ការទូទាត់ដល់រូបវ័ន្តបុគ្គល សម្រាប់ការរួមចំណែកក្នុងការគ្រប់គ្រង ការពារ ឬគ្រប់គ្រងសេវាកម្មប្រព័ន្ធអេកូឡូស៊ី។**[41] របៀបដែលការទូទាត់បែបនេះនឹងកើតឡើង របៀបយន្តការនឹងត្រូវបានអនុវត្ត និងគ្រប់គ្រង ជាដើមតម្រូវឲ្យមានការបកស្រាយឲ្យច្បាស់លាស់ ប៉ុន្តែគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចជួយសម្រួលដល់ការរួមបញ្ចូលយន្តការបែបនេះទៅក្នុងការបែងចែកអត្ថប្រយោជន៍របស់សហគមន៍តំបន់ការពារធម្មជាតិ ។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់ឲ្យច្បាស់ថា**ផលប្រយោជន៍រូបិយវត្ថុ សម្ភារៈ មិនមែនរូបិយវត្ថុ និងមិនមែនសម្ភារៈ**ដែលបានមកពីការប្រើប្រាស់ និងការគ្រប់គ្រងតំបន់សហគមន៍តំបន់ការពារធម្មជាតិគឺជាកម្មសិទ្ធិរបស់សហគមន៍។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចជួយសម្រួលដល់ការអភិវឌ្ឍន៍ និងការអនុវត្តយន្តការចែករំលែកផលប្រយោជន៍ ដោយ**ផ្តល់ការណែនាំបន្ថែមលើការចែករំលែកផលប្រយោជន៍** (*ឧ.* ប្រភេទនៃអត្ថប្រយោជន៍ ការចែករំលែកអត្ថប្រយោជន៍ផ្តេកធៀបនឹងបញ្ឈរ កត្តាដែលត្រូវពិចារណា ស្តង់ដារអប្បបរមា តម្លៃសមស្រប យន្តការដោះស្រាយវិវាទសម្រាប់កិច្ចសន្យាជាមួយភាគីទីបី) និង/ឬ ការផ្តល់**ឧទាហរណ៍ ឬគំរូ**នៃការរៀបចំ/កិច្ចព្រមព្រៀងចែករំលែកផលប្រយោជន៍។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចលើកកម្ពស់យន្តការដើម្បី**កាត់បន្ថយហានិភ័យនៃការចាប់យកអត្ថប្រយោជន៍ ឬការកាន់កាប់ដោយមនុស្សមួយចំនួនតូច** ដូចជាការបង្កើតប្រព័ន្ធដើម្បីធានាតម្លាភាព គណនេយ្យភាព និងការត្រួតពិនិត្យការចែករំលែកផលប្រយោជន៍។ ស្តង់ដារតម្លាភាពអាចត្រូវបញ្ជាក់បន្ថែម រួមទាំងការត្រួតពិនិត្យដ៏រឹងមាំដោយអង្គភាពឯករាជ្យ និងរបាយការណ៍ហិរញ្ញវត្ថុ នៃការរៀបចំការចែករំលែកផលប្រយោជន៍ទាំងអស់ដែលភ្ជាប់ទៅនឹងសហគមន៍តំបន់ការពារធម្មជាតិ (មានសក្តានុពលគ្របដណ្តប់លើអាជ្ញាធររដ្ឋាភិបាល វិស័យឯកជន។ល។)។ គោលការណ៍ណែនាំនេះក៏អាចមានយន្តការដើម្បីធានាការទទួលបាន**អត្ថប្រយោជន៍ស្មើៗគ្នា**ដោយក្រុមភាគតិច។

[41] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៦២



## គោលការណ៍៨៖ ការដាក់បញ្ចូលយន្តការសម្រាប់ដោះស្រាយជម្លោះ

ក្នុងករណីមានជម្លោះ ក្របខណ្ឌច្បាប់គួរតែធានាថាសហគមន៍ និងសមាជិកសហគមន៍ទាំងអស់អាចទទួលបានដំណោះស្រាយវិវាទដោយយុត្តិធម៌ ដែលអាចពឹងផ្អែកលើយន្តការដោះស្រាយវិវាទតាមទម្លាប់ ឬយន្តការដោះស្រាយវិវាទក្រៅតុលាការ ខណៈស្របពេលជាមួយគ្នានៅតែ ធានាថាមធ្យោបាយតុលាការ ដូចជាសាលាក្តី និងតុលាការនៅតែមានជាយន្តការក្នុងការដាក់ពាក្យបណ្តឹងផ្លូវការក៏មានផងដែរ។ ក្របខណ្ឌច្បាប់ក៏គួរតែធានាមានការ ជំនួយផ្នែកច្បាប់មានផងដែរ។

8.1 ក្របខ័ណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យសហគមន៍ប្រើប្រាស់យន្តការដោះស្រាយវិវាទដែលបានជ្រើសរើសរបស់ពួកគេផ្ទាល់ ហើយក្នុងការធ្វើដូច្នេះ ទទួលស្គាល់យន្តការដោះស្រាយវិវាទតាមទម្លាប់ ឬជំយន្តការដោះស្រាយវិវាទក្រៅតុលាការ។

8.2 ក្នុងករណីជម្លោះរវាងសហគមន៍ និងភាគីទីបី ក្របខណ្ឌច្បាប់គួរតែធានាថាមានមធ្យោបាយដើម្បីផ្តល់ដំណោះស្រាយទំនាស់សម្រាប់សហគមន៍ ដូចជាដំណោះស្រាយបែបរដ្ឋបាល ឬយន្តការដោះស្រាយទំនាស់ដែលមានចែងក្នុងកិច្ចសន្យា។

8.3 ក្របខណ្ឌច្បាប់ក៏គួរតែផ្តល់នូវការអនុញ្ញាត្តប្រើប្រាស់ប្រព័ន្ធតុលាការ ឬយន្តការដោះស្រាយវិវាទនានាដែលមានលក្ខណៈឯករាជ្យនិងអាចអនុវត្តផ្លូវច្បាប់បាន ដើម្បីឲ្យភាគីអាចដាក់ពាក្យបណ្តឹងជាផ្លូវការ ឬស្វែងរកដំណោះស្រាយ។

8.4 ក្របខណ្ឌច្បាប់ គួរតែធានាថាលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់គឺអាចរកបានយ៉ាងងាយស្រួល ដើម្បីប្រាកដបានថាគ្រប់ភាគីទាំងអស់ ជាពិសេសសហគមន៍ និងក្រុមដែលខ្វះខាតអាចទទួលបានសំណងគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាព។

## ការវាយតម្លៃ

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់ច្បាស់ថាសហគមន៍ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់**យន្តការដោះស្រាយវិវាទដែលពួកគេជ្រើសរើស ដោយទទួលស្គាល់យន្តការដោះស្រាយវិវាទតាមទម្លាប់ ឬយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។** គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបង្កើតគោលការណ៍ណែនាំច្បាស់លាស់ និងស្តង់ដារប្រតិបត្តិការសម្រាប់ការដោះស្រាយវិវាទនៅក្នុងប្រព័ន្ធសហគមន៍តំបន់ការពារធម្មជាតិដែលនៅតែគោរពតាមប្រពៃណី/ទំនៀមទម្លាប់។

នៅក្រោមគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្ន **ស្ថាប័នរដ្ឋាភិបាល**ជាច្រើនត្រូវបានផ្តល់ភារកិច្ចក្នុងការសម្របសម្រួលការដោះស្រាយជម្លោះដែលកើតឡើងនៅក្នុងសហ-គមន៍តំបន់ការពារធម្មជាតិ។[42] យ៉ាងណាមិញ មិនមាននីតិវិធី ឬស្តង់ដារដែលបានបង្កើតឡើង ដើម្បីណែនាំអង្គភាពរដ្ឋាភិបាលលើការដោះស្រាយជម្លោះនោះទេ។ ប្រសិនបើមាននីតិវិធីផ្លូវការ អាចមានប្រយោជន៍សម្រាប់សហគមន៍នៃសហគមន៍តំបន់ការពារធម្មជាតិ និងអាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងការយល់ច្បាស់អំពីការរំពឹងទុក ក្នុងចន្លោះពេលសមស្របសម្រាប់រិះរកដំណោះស្រាយ និងសម្រាប់ដំណើរការដោះស្រាយប្រកបដោយតម្លាភាព។

ក្នុងករណីមានជម្លោះរវាងសហគមនតំបន់ការពារធម្មជាតិ និងភាគីទីបី គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល**អាចធានាបាននូវមធ្យោបាយក្នុងការទាមទារ**សម្រាប់សហគមន៍ ដូចជាយន្តការរដ្ឋបាល ឬផ្អែកលើកិច្ចសន្យា។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ក៏អាចផ្តល់នូវ**ការប្រើប្រាស់ប្រព័ន្ធតុលាការ ឬយន្តការដោះស្រាយវិវាទនានា ដែលមានលក្ខណៈឯករាជ្យនិងអាចអនុវត្តផ្លូវច្បាប់បាន** ដូច្នេះភាគីអាចដាក់ពាក្យបណ្តឹងជាផ្លូវការ ឬស្វែងរកដំណោះស្រាយ។

ក្រមបរិស្ថានមានរៀបរាប់ពីបទប្បញ្ញត្តិស្តីពី**បណ្តឹងទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិ** ដោយចែងថា ភាគីត្រូវព្យាយាមដោះស្រាយបណ្តឹងតាមរយៈការសម្រុះសម្រួល មុនពេលដាក់ពាក្យបណ្តឹងទៅតុលាការ (ឬប្រសិនបើពាក្យបណ្តឹងត្រូវបានបញ្ជូនទៅតុលាការមុនការសម្រុះសម្រួល តុលាការនឹងបញ្ជូនពាក្យបណ្តឹងមកយន្តការសម្រុះសម្រួល ប្រសិនបើការសម្រុះសម្រួលមិនអាចដោះស្រាយបានទេ បណ្តឹងអាចបន្តទៅតុលាការ)។[43] ភាគីបណ្តឹងអាចដាក់ពាក្យបណ្តឹងទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត ការបញ្ឈប់ឬការទប់ស្កាត់សកម្មភាពដែលមានផលប៉ះ។[44]

ក្រមបរិស្ថានបង្កើត**គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ** នៅថ្នាក់ជាតិ និងថ្នាក់រាជធានី/ខេត្ត។[45] ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការទាំងនេះហាក់មិនដំណើរការដោយស្វ័យប្រវត្តិទេ ហើយចាំបាច់មានការរៀបចំបន្ថែមទៀត។ គ

[42] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ៤-៧ (អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន, នាយកដ្ឋានជីវភាពសហគមន៍ នៃក្រសួងបរិស្ថាន, មន្ទីរបរិស្ថានខេត្ត, នាយកតំបន់ការពារធម្មជាតិ)

[43] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៨០១ (ការសម្របសម្រួលមិនអនុវត្តចំពោះករណីរដ្ឋប្រហ្មទណ្ឌទេ)

[44] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៨០២

[45] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៨០៣-៨០៥

ណៈកម្មាធិការដោះស្រាយវិវាទទាំងនេះផ្តល់ការសម្រុះសម្រួល ប៉ុន្តែប្រសិនបើការសម្រុះសម្រួលមិនបានជោគជ័យ បណ្តឹងអាចដាក់ប្តឹងបន្តទៅតុលាការ។[46]

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចធានាថា**លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់**គឺអាចរកបានយ៉ាងងាយស្រួល (*ឧ.* ជំនួយហិរញ្ញវត្ថុ សេវាកម្មផ្លូវច្បាប់ ។ល។) ដើម្បីប្រាកដបានថាគ្រប់ភាគីទាំងអស់ ជាពិសេសសហគមន៍ និងក្រុមភាគតិចអាចទទួលបានសំណាងគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាព។

[46] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៨០៧



# គោលការណ៍ទី៩៖ ការពង្រឹងក្របខណ្ឌព្រៃសហគមន៍

ក្របខណ្ឌច្បាប់គួរកំណត់អត្តសញ្ញាណអ្វីដែលចាត់ទុកជាបទល្មើស និងបញ្ជាក់ឲ្យច្បាស់អំពីទណ្ឌកម្មដែលពាក់ព័ន្ធ ហើយអ្នកណាអាចអនុវត្ត។ ក្របខណ្ឌច្បាប់គួរតែកំណត់យ៉ាងជាក់លាក់នូវតួនាទី និងការទទួលខុសត្រូវរបស់សហគមន៍ និងអាជ្ញាធររដ្ឋាភិបាលក្នុងការពង្រឹងច្បាប់របស់ព្រៃសហគមន៍។

9.1 ក្របខណ្ឌច្បាប់គួរកំណត់ឲ្យច្បាស់នូវអ្វីដែលជាបទល្មើស និងអ្វីជាទណ្ឌកម្មដែលពាក់ព័ន្ធ។ ការដាក់ទណ្ឌកម្មគួរតែមានភាពយុត្តិធម៌ សមាមាត្រ និងបន្ទុចបង្អាក់។

9.2 ក្របខណ្ឌច្បាប់គួរតែផ្តល់សិទ្ធិអំណាចមួយចំនួន ក៏ដូចជាមធ្យោបាយ និងឧបករណ៍ចាំបាច់ដល់សហគមន៍ ដើម្បីអនុវត្តវិធាននានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងលើតំបន់ព្រៃសហគមន៍។ សិទ្ធិអំណាចនេះអាចរាប់បញ្ចូលទាំងការចាត់វិធានការប្រឆាំងនឹងសមាជិកសហគមន៍ ឬភាគីទីបីចំពោះការប្រព្រឹត្តខុស។ ប្រសិនបើមិនអនុញ្ញាតឲ្យចាត់វិធានការដោយផ្ទាល់ប្រឆាំងនឹងភាគីទីបី នោះក្របខណ្ឌច្បាប់គួរតែបញ្ជាក់ឲ្យច្បាស់ថាតើសកម្មភាពអ្វីខ្លះដែលអាចអនុវត្តសម្រាប់សហគមន៍។

9.3 ក្របខណ្ឌច្បាប់គួរចែងនូវប្រភេទនៃទណ្ឌកម្ម ឬវិធានការផ្សេងទៀតដែលសហគមន៍អាចអនុវត្ត ដូចជាការស្តីបន្ទោស ឬការព្រមានជាដើម។ ការដាក់ទណ្ឌកម្មបែបនេះគួរតែត្រូវបានកំណត់ក្នុងច្បាប់/គោលការណ៍ផ្ទៃក្នុងរបស់សហគមន៍ (ឧទាហរណ៍ លក្ខន្តិកៈ)។

9.4 ក្របខណ្ឌច្បាប់គួរកំណត់ស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការអនុវត្ត និងការអនុវត្តច្បាប់នៃព្រៃសហគមន៍។ ការកំណត់នេះគប្បីបញ្ជាក់អំពីរបៀបអនុវត្តការត្រួតពិនិត្យ និងការអនុវត្តច្បាប់។ ការផ្តល់ជូនធនធានហិរញ្ញវត្ថុ និងធនធានមនុស្សគ្រប់គ្រាន់ក៏គួរតែមាន ដើម្បីធានាថាកិច្ចការងារត្រួតពិនិត្យ និងការអនុវត្តច្បាប់អាចសម្រេចបានពេញលេញ។

9.5 ជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យ ក្របខណ្ឌច្បាប់គួរតម្រូវឲ្យមានការវាយតម្លៃលើការបំពេញកាតព្វកិច្ចរបស់សហគមន៍ពាក់ព័ន្ធនឹងព្រៃឈើ និងមានយន្តការជូនដំណឹងផ្លូវការ ដើម្បីអនុញ្ញាតឲ្យពួកគេអនុវត្តវិធានការផ្សះផ្សារប៉ះប៉ូវ មុនពេលការដាក់ទណ្ឌកម្ម។ ក្របខណ្ឌច្បាប់ក៏គួរតែផ្តល់នូវយន្តការបណ្តឹងសា

ទុក្ខផងដែរ ប្រសិនបើមានការដាក់ទណ្ឌកម្ម ជាពិសេសសម្រាប់ទណ្ឌកម្មធ្ងន់ធ្ងរ ដូចជាការលុប/ដកហូតតំបន់ព្រៃសហគមន៍ដែលបានបែងចែក។

## ការវាយតម្លៃ

ការកំណត់**បទល្មើស និងការដាក់ទណ្ឌកម្មដែលពាក់ព័ន្ធ**ឲ្យមានភាពច្បាស់លាស់ និងការកំណត់ការដាក់ទណ្ឌកម្មឲ្យមានភាពយុត្តិធម៌ សមាមាត្រ និងបន្ទុចបង្អាក់ មានអត្ថប្រយោជន៍ក្នុងការអនុវត្ត។ បទល្មើស និងការពិន័យមួយចំនួនមានចែងនៅក្នុងក្រមបរិស្ថាន.[47]

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចផ្តល់**សិទ្ធិអំណាចមួយចំនួនដល់សហគមន៍** ក៏ដូចជាមធ្យោបាយ និងឧបករណ៍ចាំបាច់ ដើម្បីអនុវត្តច្បាប់ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិរបស់ពួកគេ។ សិទ្ធិអំណាចទាំងនេះ អាចរួមមានការចាត់វិធានការប្រឆាំងនឹងសមាជិកសហគមន៍ ឬភាគីទីបីចំពោះការប្រព្រឹត្តខុស។ ប្រសិនបើមិនអនុញ្ញាតឲ្យចាត់វិធានការលើភាគីទីបីដោយផ្ទាល់ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចបញ្ជាក់ឲ្យច្បាស់ថាតើសកម្មភាពអ្វីខ្លះដែលសហគមន៍តំបន់ការពារធម្មជាតិអាចចាត់វិធានការបាន។ ក្រមបរិស្ថានបានអំពាវនាវឲ្យមានការកែលម្អការអនុវត្តច្បាប់តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអ្នកដទៃ រួមទាំងសហគមន៍មូលដ្ឋានផងដែរ។[48]

នៅក្រោមគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្ន សមាជិកសហគមន៍តំបន់ការពារធម្មជាតិនៅមានកម្រិតក្នុងការអនុវត្តច្បាប់ ដូចជាតាមរយៈការរាយការណ៍ ពីការល្មើសច្បាប់ ឬលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិទៅកាន់អាជ្ញាធររដ្ឋាភិបាល និងសហការជាមួយអាជ្ញាធរនៅពេលចាំបាច់ និងមិនត្រូវបានអនុញ្ញាតឲ្យចាត់វិធានការអនុវត្តច្បាប់ដោយផ្ទាល់ ឬដាក់ទណ្ឌកម្មដោយខ្លួនឯងឡើយ។ **ការអនុញ្ញាតឲ្យសហគមន៍នៃសហគមន៍តំបន់ការពារធម្មជាតិចាត់វិធានការអនុវត្តច្បាប់** (*ឧ.* ការឃុំខ្លួនជនល្មើសបណ្តោះអាសន្ន ការរឹបអូសឧបករណ៍ខុសច្បាប់ ការដើរល្បាតរួមគ្នាជាប្រចាំ) អាចធ្វើឲ្យការគ្រប់គ្រងជាទូទៅនៃធនធានធម្មជាតិនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ/តំបន់ការពារធម្មជាតិ។ ចំណុចនេះអាចបន្ថែមដោយការផ្តល់មូលនិធិ និងធនធានគ្រប់គ្រាន់សម្រាប់ការដើរល្បាត និងការអនុវត្តច្បាប់ផ្សេងៗទៀត។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលអាចកំណត់នូវ**ប្រភេទនៃការដាក់ទណ្ឌកម្មឬវិធានការផ្សេងទៀត** ដែលសហគមន៍នៃសហគមន៍តំបន់ការពារធម្មជាតិអាចអនុវត្តដូចជាការស្តីបន្ទោស ឬការព្រមានជាដើម។

ក្រមបរិស្ថានបានកំណត់**មន្ត្រីដែលទទួលខុសត្រូវចំពោះតំបន់ការពារធម្មជាតិ** (នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និង**មន្ត្រីអធិការកិច្ច**។[49] ការបញ្ជាក់បន្ថែមនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួលថាតើទំនួលខុសត្រូវរបស់មន្ត្រីទាំងនោះទាក់ទងនឹងការអនុវត្ត និងការអនុវត្តច្បាប់នៅសហគមន៍តំបន់ការពារធម្មជាតិយ៉ាងដូចម្តេច។ ចំណុចនេះអាចប៉ះពាល់ដល់ការចាត់តាំងនៃទំនួលខុសត្រូវបច្ចុប្បន្ន ដែលជាបញ្ហាជាក់ស្តែង មន្ទីរបរិស្ថានខេត្ត មានទំនួលខុសត្រូវដឹកនាំក្នុងកិច្ចការអនុវត្តច្បាប់ទាក់ទងនឹងសហគមន៍តំបន់ការពារធម្មជាតិប្រចាំថ្ងៃ ដោយសហការជាមួយអគ្គនាយកដ្ឋានសហគម

[47] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៨២៤-៨២៥, ៨២៧-៨២៨, ៨៤៩-៨៥១
[48] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៤៨៦
[49] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា៨១០, ៨១៥, ៨១៦

ន៍មូលដ្ឋានរបស់ក្រសួងបរិស្ថាន និងនាយកសហគមន៍តំបន់ការពារធម្មជាតិនីមួយៗទទួលខុសត្រូវចំពោះការចាត់វិធានការប្រឆាំងនឹងបទល្មើសធនធានធម្មជាតិនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ។[50]

នៅក្រោមគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបច្ចុប្បន្ន បង្ហាញថា**សំណង**មួយចំនួនអាចត្រូវបានបង់ទៅឲ្យសហគមន៍នៃសហគមន៍តំបន់ការពារធម្មជាតិ សម្រាប់បទល្មើសធនធានធម្មជាតិមួយចំនួន ប៉ុន្តែមិនមានការកំណត់ច្បាស់លាស់ទេ។[51] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចបញ្ជាក់អំពីសំណងដែលសហ-គមន៍តំបន់ការពារធម្មជាតិអាចទទួលបាន សម្រាប់បទល្មើសធនធានធម្មជាតិ និងរបៀបដែលសំណងត្រូវបានផ្តល់ និងបែងចែក។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចបង្កើត**យន្តការជូនដំណឹងផ្លូវការ**ដើម្បីអនុញ្ញាតឲ្យសហគមន៍តំបន់ការពារធម្មជាតិធ្វើការប៉ះប៉ូវ មុនពេលមានការដាក់ទណ្ឌកម្ម ក្នុងករណីដែលសហគមន៍មិនបានបំពេញកាតព្វកិច្ចពេញលេញ។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ក៏អាចផ្តល់នូវយន្តការ**បណ្តឹងសាទុក្ខ**ផងដែរ ប្រសិនបើមានការដាក់ទណ្ឌកម្ម ជាពិសេសសម្រាប់ទណ្ឌកម្មធ្ងន់ធ្ងរ ដូចជាការលុបចោលការបង្កើតសហគមន៍តំបន់ការពារធម្មជាតិជាដើម។

[50] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ប្រការ ៧

[51] មាត្រាមួយក្នុងទម្រង់គំរូលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិដែលមាននៅក្នុងឧបសម្ព័ន្ធទី៣ នៃគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិបានបញ្ជាក់ថា៖ "គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអាចទាមទារសំណងខូចខាតពីបទល្មើសថ្នាក់ទី១ ស្របតាមមាត្រា ៥៦ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។" ដោយសារខ្លឹមសារនេះមាននៅក្នុងឧទាហរណ៍នៃទម្រង់គំរូលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានតាក់តែងឡើងដោយផ្អែកលើកត្តាពិសេសមួយចំនួនដែលមានវត្តមាននៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ វាមានភាពមិនច្បាស់លាស់ថាតើសហគមន៍តំបន់ការពារធម្មជាតិមានភាពបត់បែនប៉ុណ្ណាក្នុងការអភិវឌ្ឍវិធានការសម្រាប់សំណងខូចខាតក្នុងសហគមន៍ជាក់លាក់របស់ពួកគេ (*ឧ.*តើគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអាចទាមទារសំណងខូចខាតពីបទល្មើសថ្នាក់ទី៤ដែរឬទេ?)។ ចំណុចនេះ ចាំបាច់ត្រូវការធ្វើការបច្ចុប្បន្ន ដើម្បីស្របជាមួយនឹងក្រមបរិស្ថាន និងធនធានធម្មជាតិ.



## គោលការណ៍ទី១០៖ ការផ្តល់ជំនួយខាងក្រៅដល់សហគមន៍

ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យតួអង្គខាងក្រៅដូចជា អង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាល វិស័យឯកជន ឬស្ថាប័នអន្តរជាតិ ផ្តល់ជំនួយក្នុងគ្រប់ទម្រង់ដល់សមាជិកសហគមន៍ក្នុងការចូលប្រើប្រាស់ និងអនុវត្តព្រៃសហគមន៍។ ក្របខណ្ឌច្បាប់ក៏គួរតែបង្កើតឲ្យបានច្បាស់លាស់នូវមធ្យោបាយ និងស្ថាប័នចាំបាច់សម្រាប់ការគាំទ្រពីខាងក្រៅក្នុងការផ្តល់ជំនួយ។

10.1 ក្របខណ្ឌច្បាប់គួរកំណត់ច្បាស់លាស់នូវស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធដែលនឹងចូលរួមក្នុងការគាំទ្រព្រៃសហគមន៍ រួមមានការបំពេញបេសកកម្ម និងមុខងាររបស់ព្រៃសហគមន៍។ ក្របខណ្ឌច្បាប់ ក៏គួរបញ្ជាក់ឲ្យច្បាស់អំពីរបៀបដែលអង្គភាពរដ្ឋាភិបាលតាមវិស័យ នឹងសម្របសម្រួលលើបញ្ហាទាក់ទងនឹងព្រៃសហគមន៍។ អាជ្ញាធរពាក់ព័ន្ធគប្បីដាក់ឲ្យដំណើរការ និងបន្តអនុវត្តនូវវិធីសាស្រ្តជាក់លាក់តាមកម្មវិធី ហើយគប្បីផ្តល់នូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបំពេញបេសកកម្ម។

10.2 ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលផ្តល់ការគាំទ្រដល់សហគមន៍។ ក្របខណ្ឌច្បាប់ក៏គួរតែបញ្ជាក់ឲ្យច្បាស់ផងដែរ ថាតើមានលក្ខខណ្ឌណាមួយដែលអង្គការមិនមែនរដ្ឋាភិបាលត្រូវតែបំពេញ ដើម្បីផ្តល់ការគាំទ្របែបនេះ ហើយតើលក្ខខណ្ឌទាំងនោះមានអ្វីខ្លះ។ លក្ខខណ្ឌទាំងនេះមិនគួរមានលក្ខណៈស្មុគស្មាញពេកឡើង ដូចជាច្បាប់ស្តីពីការចុះបញ្ជីសមាគម និង ប្រតិបត្តិការជាអង្គការមិនមែនរដ្ឋាភិបាល។

10.3 ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យមានការចូលរួមពីតួអង្គវិស័យឯកជននៅក្នុងព្រៃសហគមន៍ តែស្របពេលជាមួយគ្នានោះ មានការធានាឲ្យមានទំនាក់ទំនងតុល្យភាពរវាងសហគមន៍ និងតួអង្គ វិស័យឯកជន និងកាត់បន្ថយហានិភ័យនៃការទន្ទ្រានព្រៃសហគមន៍ដោយតួអង្គវិស័យឯកជន។

10.4 ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យស្ថាប័នអន្តរជាតិផ្តល់ការគាំទ្រដល់ព្រៃសហគមន៍។ ក្របខណ្ឌច្បាប់គួរតែអនុញ្ញាតឲ្យមានការគាំទ្រដោយផ្ទាល់ដល់សហគមន៍។ ក្នុងករណីដែលការគាំទ្រដោយផ្ទាល់អាចមិនអាចប្រព្រឹត្តទៅបាន ក្របខណ្ឌច្បាប់គួរកំណត់ឲ្យច្បាស់អំពីរបៀបដែលការគាំទ្រអាចផ្តល់ជូន។

# ការវាយតម្លៃ

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចជួយសម្រួលដល់ការគាំទ្រជាច្រើនពីតួអង្គខាងក្រៅទៅកាន់សហគមន៍តំបន់ការពារធម្មជាតិ។ ចំពោះ**ការគាំទ្ររបស់រដ្ឋាភិបាល** គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចកំណត់អត្តសញ្ញាណស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាលដែលមានភារកិច្ចគាំទ្រការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ រួមទាំងបេសកកម្ម និងមុខងាររបស់សហគមន៍។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ក៏អាចបញ្ជាក់ពីរបៀបដែលអង្គភាពរដ្ឋាភិបាលតាមវិស័យ នឹងសម្របសម្រួលលើបញ្ហាទាក់ទងនឹងសហគមន៍តំបន់ការពារធម្មជាតិ។

ក្រមបរិស្ថានបានបង្ហាញអំពី**យន្តការមូលនិធិ**ផ្សេងៗ ដែលអាចត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល។ ក្រមបរិស្ថាន បានប្រមើលមើលការបង្កើតមូលនិធិបរិស្ថាន និងសង្គម ដែលអាចប្រើប្រាស់សម្រាប់ការផ្តល់ការគាំទ្រលើការបង្កើតនិងការអភិវឌ្ឍសហគមន៍មូលដ្ឋាន; គម្រោងអភិវឌ្ឍន៍របស់សហគមន៍មូលដ្ឋាន រួមទាំងការផ្តល់មីក្រូហិរញ្ញវត្ថុជាមូលនិធិសម្រាប់បង្វិល; ការបណ្តុះបណ្តាលធនធានមនុស្ស; និងសកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ។[52] យ៉ាងណាមិញ ជាដំបូងចាំបាច់ត្រូវបង្កើតគណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គម (ដែលនឹងគ្រប់គ្រងមូលនិធិបរិស្ថាន និងសង្គម) និងរបៀបដែលមូលនិធិបរិស្ថាននិងសង្គមនឹងដំណើរការ។[53]

គេរំពឹងថា **មូលនិធិបរិស្ថាននិងសង្គម** នឹងទទួលបានមូលនិធិពីទុនដំបូងរបស់រាជរដ្ឋាភិបាល; ភាគទានបានមកពីអាករពិសេសពាក់ព័ន្ធវិស័យបរិស្ថានតាមការកំណត់របស់រាជរដ្ឋាភិបាល; ភាគទានបានមកពីកម្រៃសេវាវិស័យអាកាសចរស៊ីវិលតាមការកំណត់របស់រាជរដ្ឋាភិបាល; បុព្វលាភបានមកពីម្ចាស់គម្រោងអភិវឌ្ឍឯកជននិងសាធារណៈ ដែលមានចែងនៅក្នុងផែនការគ្រប់គ្រង បរិស្ថាននៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬកិច្ចសន្យាការពារបរិស្ថាន; ប្រាក់ចំណូលបានមកពីកិច្ចគាំពារបរិស្ថានសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងអភិរក្សជីវៈចម្រុះ; វិភាគទានបានមកពីមូលនិធិទាយជ្ជទានបរិស្ថាន[54]; វិភាគទានបានមកពីមូលនិធិតំបន់ការពារធម្មជាតិ[55]; វិភាគទានបានមកពីកម្រៃសេវាលក់សំបុត្រចូលទស្សនាតំបន់ការពារធម្មជាតិ; កម្រៃសេវាកម្មជួលទីតាំងដំឡើងបង្គោលអង់តែន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត; ភាគទានបានមកពីកម្រៃជួលទីតាំងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិទំហំក្រោម១០ហិកតា; ភាគទានបានមកពីការលក់ឥណទានកាបូន; ប្រាក់ដែលបានមកពីការដោះស្រាយបណ្តឹង; អំណោយឬជំនួយថវិកា សម្ភារៈ ឧបករណ៍នានាពីអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា; វិភាគទានបានមកពីកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងវិស័យបរិស្ថាន; និងប្រភពផ្សេងៗទៀត។[56]

---

[52] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៦៩, ៧៧១

[53] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៧២

[54] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៦៧

[55] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៦៨

[56] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៧០

ក្រមបរិស្ថានក៏បានណែនាំអំពី**បរធនបាលកិច្ចបរិស្ថាន**[57] ក៏ដូចជា**បរធនបាលកិច្ចបរិស្ថានសម្រាប់ការគ្រប់គ្រងរួមគ្នា**ផងដែរ។[58] បរធនបាលកិច្ចបរិស្ថានសម្រាប់ការគ្រប់គ្រងរួមគ្នា ត្រូវបានរៀបចំឡើងដើម្បីផ្ដល់ការគាំទ្រដល់សកម្មភាពនៃការគ្រប់គ្រងរួមគ្នាដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងរួមគ្នានីមួយៗ។ បរធនបាលកិច្ចបរិស្ថានសម្រាប់ការគ្រប់គ្រងរួមគ្នា ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគ្រប់គ្រងរួមគ្នា (ត្រួតពិនិត្យ តាមដាន និងវាយតម្លៃដោយក្រសួងបរិស្ថាន) ហើយគណៈកម្មាធិការគ្រប់គ្រងរួមគ្នាអាចទទួលបានថវិកា និងរកចំណូលពីប្រភពដែលមានជាអាទិ៍ មូលនិធិសង្គមនិងបរិស្ថាន; ការបរិច្ចាគដោយផ្ទាល់ពីវិស័យឯកជន និងសាធារណៈ; សេវានានា ការយកថ្លៃឈ្នួល ថ្លៃប្រើប្រាស់ ថ្លៃកម្សាន្ត ឬថ្លៃចូលទស្សនា; និងវិភាគទាន អំណោយ និងជំនួយផ្សេងទៀត។

ក្រមបរិស្ថានបានកំណត់ថាការប្រើប្រាស់**ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗ** ដែលទទួលបានតាមរយៈការអនុវត្តនៃការគ្រប់គ្រងរួមគ្នា ត្រូវប្រើប្រាស់សម្រាប់តែផលប្រយោជន៍របស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា សម្រាប់គាំទ្រសកម្មភាពគ្រប់គ្រងរួមគ្នា និងសម្រាប់ការអភិរក្សនៃតំបន់គ្រប់គ្រងរួមគ្នា និងបណ្ដាតំបន់នៅជាប់តំបន់ការពារធម្មជាតិ។[59] វិធីសាស្ត្រច្បាស់លាស់ក្នុងការបែងចែកចំណូល ការចំណាយ ឬវិភាគទានផ្សេងៗត្រូវកំណត់ក្នុងកិច្ចព្រមព្រៀងស្ដីពីការគ្រប់គ្រងរួមគ្នា។[60] ក្រមបរិស្ថានក៏ចែងផងដែរថា ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗ ដែលទទួលបានពីការងារគ្រប់គ្រងនៃសហគមន៍គ្រប់គ្រងរួមគ្នាត្រូវទទួល អាទិភាពសម្រាប់ការលើកលែងពន្ធអាករ និងបន្ទុកផ្សេងទៀត។

វាអាចមានប្រយោជន៍សម្រាប់គោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ដើម្បីបង្ហាញពី**ការបែងចែកមូលនិធិអប្បបរមា**ពីប្រភពមូលនិធិដែលអាចអនុវត្តបាន ដែលនឹងត្រូវបានឧទ្ទិសដល់ការបង្កើត ការគ្រប់គ្រង និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ ។ នេះនឹងជួយធានាឲ្យបានទៀងទាត់ ដែលអាចទុកចិត្តបាន និងសមត្ថភាព និងថវិកាគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ។ លើសពីនេះ វានឹងមានប្រយោជន៍សម្រាប់គោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ដើម្បីដោះស្រាយពីរបៀបដែលការផ្ដល់មូលនិធិបែបនេះអាចចូលប្រើបានដោយសហគមន៍នៃសហគមន៍តំបន់ការពារធម្មជាតិ (*ឧ.* យន្តការដែលត្រូវបង្កើតឡើង លក្ខណៈវិនិច្ឆ័យដែលអាចអនុវត្តបានសម្រាប់សហគមន៍ នៃសហគមន៍តំបន់ការពារធម្មជាតិ ប្រសិនបើមាន ដូចជាការបង្កើតគណនីធនាគារជាដើម)។

គោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអនុញ្ញាតឲ្យ**អង្គការមិនមែនរដ្ឋាភិបាល**ផ្ដល់ការគាំទ្រ។ ក្រមបរិស្ថានលើកទឹកចិត្តឲ្យអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យឯកជនចូលរួម និងសម្របសម្រួលដំណើរការរៀបចំ និងការអនុវត្តរបស់[61] ដើម្បីគាំទ្រការចូលរួមនេះ គោលការណ៍ណែនាំស្ដីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចបញ្ចូលគោលការណ៍ណែនាំប្រតិបត្តិការដែលបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងអាជ្ញាធរ។ គោលការណ៍ណែនាំប្រតិបត្តិការ គួរត្រូវបានបង្កើតឡើងយ៉ាង

[57] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៧៣-៧៩២

[58] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៩៣

[59] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៧៩៤

[60] "កិច្ចព្រមព្រៀងការគ្រប់គ្រងរួមគ្នា" មិនត្រូវបានកំណត់និយមន័យនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិនោះទេ ប៉ុន្តែយើងអាចសន្មតថាសំដៅទៅលើកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងសកម្មភាពគ្រប់គ្រងរួម (សូមមើលលេខយោងលេខ៣៨ សម្រាប់ការពិពណ៌នាអំពីការយល់ដឹងទូទៅនៃ "កិច្ចព្រមព្រៀងការគ្រប់គ្រងរួមគ្នា")។

[61] ក្រមបរិស្ថាន និងធនធានធម្មជាតិ មាត្រា ៣៧៣

ម៉ត់ចត់ ដើម្បីកុំឲ្យមានផលប៉ះពាល់ដោយអចេតនានៃការរឹតត្បិត និង/ឬមិនរាប់បញ្ចូលការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្ត។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល ក៏អាចអនុញ្ញាតិឲ្យ**តួអង្គក្នុងវិស័យឯកជន**សហការជាមួយសហគមន៍តំបន់ការពារធម្មជាតិ។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចធានាថាការការពារសម្រាប់ការចូលរួមប្រភេទនេះត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយហានិភ័យនៃការទន្ទ្រានដោយអភិជន និង/ឬជនដែលមានទំនាក់ទំនងនឹងវិសមភាពអំណាច។

គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចអនុញ្ញាតឲ្យ**ស្ថាប័នអន្តរជាតិ**ផ្តល់ការគាំទ្រដោយផ្ទាល់ដល់សហគមន៍តំបន់ការពារធម្មជាតិ។ គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល អាចជួយសម្រួលដល់ការគាំទ្រដោយផ្ទាល់ ដោយដោះស្រាយលក្ខណៈវិនិច្ឆ័យនានាដែលសហគមន៍តំបន់ការពារធម្មជាតិត្រូវតែបំពេញ (ប្រសិនបើមាន) ដើម្បីទទួលបានការគាំទ្រដោយផ្ទាល់។ ក្នុងករណីដែលការគាំទ្រដោយផ្ទាល់មិនអាចប្រព្រឹត្តទៅបាន គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានកែសម្រួល គួរកំណត់ឲ្យច្បាស់អំពីរបៀបដែលការគាំទ្រអាចត្រូវបានផ្តល់ជូន។

## សេចក្តីថ្លែងអំណរគុណ

អត្ថបទវិភាគនេះត្រូវបានតាក់តែងឡើងដោយ Yena Kwon ដែលជាទីប្រឹក្សាច្បាប់ និងគោលនយោបាយបរិស្ថានអន្តរជាតិ និងអ្នកចូលរួមបង្កើតគោលការណ៍ណែនាំអាស៊ានសម្រាប់ក្របខណ្ឌច្បាប់ព្រៃសហគមន៍ប្រកបដោយប្រសិទ្ធិភាព សម្រាប់ClientEarth.

អត្ថបទវិភាគនេះក៏ត្រូវបានត្រួតពិនិត្យឡើងវិញ ទទួលការចូលរួមផ្នែកបច្ចេកទេស និងមតិយោបល់ពី Tol Sokchea (RECOFTC), សាត់ កញ្ញារ៉ា (ទីប្រឹក្សាឯករាជ្យ), Amalia Rodriguez Fajardo (ClientEarth), Babette Tachibana-Brophy (ClientEarth) និង Mira Hayden (ClientEarth).


ClientEarth

ClientEarth គឺជាអង្គការសប្បុរសធម៌ដែលបានចុះបញ្ជី ដែលប្រើប្រាស់អំណាចនៃច្បាប់ដើម្បីការពារមនុស្ស និងភពផែនដី។


ClientEarth ទទួលបានមូលនិធិពីការគាំទ្រដ៏សប្បុរសរបស់មូលនិធិសប្បុរសធម៌នានា ម្ចាស់ជំនួយក្នុងទម្រង់ស្ថាប័ន និងបុគ្គលដែលចូលរួម។